ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jun-2013, 10:25
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី១៩៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោកស្រី មីរាម ម៉ាហ្វេសសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក រេយ៍ន័រ ឃីត *(Mr. Keith RAYNOR)*

កញ្ញា សុង ឆរ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក វ៉េន ពៅ

លោក បេនី យ៉េ *(Ms. Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក នូ ម៉ៅ (TCW-801) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នូ ម៉ៅ** (TCW-801)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ......ទំព័រ ១
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី......ទំព័រ ១៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅថ្ងៃនេះអង្គជំនុំជម្រះបន្តស្តាប់សក្ខីសាក្សី នូ ម៉ៅ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តី។

លោក នូ ម៉ៅ ហើយកាលពីម្សិលមិញអង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកមានបញ្ហាសុខភាពនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មចុងក្រោយនៅពេលរសៀល។ ហើយនៅថ្ងៃនេះទី១ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកអាចប្រើប្រាស់នូវភេសជ្ជៈដែលរៀបចំទុកសម្រាប់លោកដើម្បីបន្តកម្លាំង។ ហើយទី២ ប្រសិនបើលោកមានបញ្ហាសុខភាពអាចលើកដៃ ឬក៏ប្រាប់ទៅមេធាវីប្រឹក្សានៅជិតលោកនោះ ដើម្បីសម្រាកមួយរយៈខ្លី ឬក៏ពេលវេលាសមស្រប ដើម្បីអាចមានកម្លាំងនឹងបន្តផ្តល់សក្ខីកម្មរហូតដល់ចប់។

ហើយលោកមេធាវីប្រឹក្សាសាក្សីជួយសម្របសម្រួលសាក្សីផង ដើម្បីឲ្យគាត់មានសមត្ថភាពនិងលទ្ធភាពអាចឆ្លើយតបទៅនឹងសំណួរដែលនឹងសួរដេញដោលនៅក្នុងអំឡុងពេលនៃដំណើរការសវនា-ការបញ្ចប់ការស្តាប់សក្ខីកម្មរបស់គាត់នាពេលថ្ងៃនេះ។

បាទជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បី បន្តការទាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីភាគីទាំងអស់។ សួស្តីលោកសាក្សី ខ្ញុំមានសំណួរមួយចំនួន តិចតែប៉ុណ្ណោះសម្រាប់នៅក្នុងថ្ងៃនេះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរដំបូងគឺ កាលពីម្សិលមិញលោកបានឆ្លើយថា លោកបានចូលបដិវត្តន៍។ សូមលោកជួយពន្យល់។ ហេតុអ្វីបានជាមានបដិវត្តន៍កើតឡើងដូច្នេះ? តើបដិវត្តន៍ហ្នឹងគេធ្វើដើម្បីគោលបំណងអ្វីដែរ?

[០៩:០៤:៤០]

**លោក នូ ម៉ៅ៖**

**ឆ៖** បដិវត្តន៍គោលបំណងបដិវត្តន៍ គឺធ្វើគោលបំណងហ្នឹង ចូលរួមៗបំផុសចលនាប្រជាជនធ្វើបដិវត្តន៍ ដើម្បីដេញចក្រពត្តិ គេហៅថា ចក្រពត្តិអាមេរិកាំង។ ខ្ញុំបានដឹងប៉ុណ្ណឹងទេ។

**ស៖** តើលោកដឹងទេបដិវត្តន៍ហ្នឹងចាប់ផ្តើមនៅពេលណាដែរ?

**ឆ៖** វាភ្លាំងភ្លាត់ រឿងការចងចាំហ្នឹងមិនដឹងទេ ទាល់តែមើលក្នុងឯកសារបានដឹង តែនៅក្នុងនោះមានឯកសារនៅក្នុង កត់ត្រានៅក្នុងកាសែតដែលលោកសម្ភាសជាមួយខ្ញុំនោះ។

**ស៖** លោកសាក្សី តើលោកដឹងទេបក្សកុម្មុយនីស្តកម្ពុជានេះបង្កើតឡើងក្នុងពេលណាដែរ? ក្នុងឆ្នាំណាដែរ?

**ឆ៖** បក្សកម្ពុជាដែលកើតឡើងឆ្នាំមួយពាន់ -- ខ្ញុំអត់បានចាំហ្នឹងហើយ ដូចអង្គាល់កើតគណៈបក្ស បើនិយាយទៅវាទាល់តែការពិតដែរ តែវាភ្លេចបាត់ទៅក្នុងឆ្នាំខែអី វា -- ខ្ញុំអត់បានចងចាំទេ។

**ស៖** កាលពីម្សិលមិញលោកសាក្សី លោកបានឆ្លើយអំពីពណ៌ក្រហម ហើយលោកក៏និយាយពាក់ព័ន្ធថាពណ៌ក្រហមនេះគឺយោងទៅលើបញ្ហាខ្មែរក្រហម ហើយលោកថាក្រហមនេះសំដៅលើឈាម ហើយតើលោកដឹងទេ ហេតុផលអ្វីបានជាគេដាក់ឈ្មោះថា "ខ្មែរក្រហម" ថាខ្មែរក្រហមអីចឹង? ឬក៏តាមលោកនោះ តើពណ៌ក្រហមហ្នឹងមានន័យយ៉ាងម៉េច?

[០៩:០៧:៥៨]

**ឆ៖** តាមយល់របស់ខ្ញុំដែលឃើញថា ខ្មែរក្រហមធ្វើបដិវត្តន៍ហ្នឹង ដាក់ឈ្មោះថា "ខ្មែរក្រហម" បើទស្សនៈខ្ញុំផ្ទាល់ខ្ញុំថា ខ្មែរក្រហមត្រូវមានការប្រឡាក់ឈាមដៃចំពោះអ្នកប្រជាជនដែលក្រោកឡើងតស៊ូ គេឲ្យធ្វើ។ ខ្មែរក្រហមបានន័យថា "ឈាម" ហ្នឹងហើយ។ ឈាមខ្មែរដែលប្រឡាក់ដោយការកាប់សម្លាប់។

**ស៖** ខ្ញុំឯកភាពជាមួយលោក លោកសាក្សី។ ក្រហមនេះគឺពណ៌ឈាមមែន ក៏ប៉ុន្តែលោកដឹងទេថា ពណ៌ក្រហមនេះវាមានន័យផ្សេងទេ នៅពេលដែលគេនិយាយសំដៅទៅលើបក្សកុម្មុយនីស្តកម្ពុជានោះ។ តើលោកដឹងទេ?

**ឆ៖** ខ្ញុំអត់បានដឹងដែរត្រង់ហ្នឹង។

**ស៖** លោកសាក្សីតើគណៈ -- តើលោកស្គាល់ លោកដឹងទេអ្វីទៅជាគណៈកម្មាធិការអចិន្ត្រៃយ៍

នៃបក្សកុម្មុយនីស្តកម្ពុជានោះ?

**ឆ៖** គណបក្សកម្ពុជា ខ្ញុំមិនយល់ដឹងថា ការដែលចង់បង្កើតជាគណបក្សកម្ពុជា ខ្ញុំមិនយល់ថា ចុះហេតុអ្វីបានជាបង្កើតបក្សកម្ពុជា។ នេះជាទស្សនៈរបស់ខ្ញុំដែលខ្ញុំយល់ថា គណបក្សកម្ពុជានេះគឺគេលើកឡើងថាត្រូវតែមានការតស៊ូ ហើយប្រឆាំងនឹងរបបលន់ នល់ ហ្នឹង។

[០៩:១០:៤៥]

**ស៖** ខ្ញុំសូមសួរដូច្នេះវិញ។ នៅពេលដែលលោកចូលបដិវត្តន៍ ក្រោយៗឆ្នាំដែលលោកចូលបដិវត្តន៍នេះ លោកដែលធ្លាប់ឮពាក្យថាគណៈអចិន្ត្រៃយ៍ ឬក៏គណៈកម្មាធិការអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ខ្ញុំបាទអត់បានដឹងថា -- សុំម្តងទៀត សូមបញ្ជាក់សំណួរឲ្យខ្ញុំបានដឹង វាចេះតែភ្លេចបាទ។

**ស៖** ខ្ញុំអធ្យាស្រ័យ។ តើលោកធ្លាប់ឮពាក្យគណៈមជ្ឈិមនៃបក្សកុម្មុយនីយកម្ពុជាដែរឬទេ? តើលោកធ្លាប់ឮគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** បាទហ្នឹងហើយ គណបក្សកម្ពុជាដែលបង្កើតឡើង មានការរៀបចំធ្វើបដិវត្តន៍។ ដែលខ្ញុំយល់ប៉ុណ្ណឹង អស់។

**ស៖** តើលោកនៅចាំទេថា បក្សកុម្មុយនីស្តកម្ពុជាមានបោះពុម្ពជាទស្សនាវដ្តីរបស់ខ្លួននាពេលនោះ ដែលនៅក្នុងទស្សនាវដ្តីនោះបានរៀបរាប់បង្ហាញថា អ្វីទៅជាបដិវត្តន៍។ តើលោកធ្លាប់បានដឹងទេ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំអត់បានដឹងដែរ។

**ស៖** តើលោកធ្លាប់បានអានឯកសារណាមួយដែរឬទេ ឬក៏ឯកសារបោះពុម្ពផ្សាយនាពេលនោះដែរឬទេ ដែលឯកសារនោះរៀបរាប់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីលោកចូលធ្វើបដិវត្តន៍នោះ?

[០៩:១៣:៣៧]

**ឆ៖** ខ្ញុំអត់បានមើលកាសែតដែលបោះពុម្ពផ្សព្វផ្សាយឲ្យប្រជាជននោះ ខ្ញុំអត់ដែលបានឃើញបានមើលកាសែតហ្នឹងផង។

**ស៖** តើទស្សនាវដ្តីទង់បដិវត្តនោះ តើលោកទឹកឃើញ លោកធ្លាប់ឮទេ?

**ឆ៖** ខ្ញុំអត់បាន អត់បានឮទេ ទង់បដិវត្តនោះ មិនដឹងជាទង់នោះ វាជារូបខេត្តតំណាងឲ្យយ៉ាងម៉េចក៏ខ្ញុំអត់បានដឹងដែរត្រង់ហ្នឹង។

**ស៖** តើលោកដែលឮពាក្យថា “ទង់ក្រហម” ទេ?

**ឆ៖** ដែលពួទង់ក្រហម។

**ស៖** តើលោកនៅចាំអ្វីខ្លះអំពីទង់ក្រហមនេះ?

**ឆ៖** ទង់ក្រហមហ្នឹង ខ្ញុំដូចជាបាត់បង់ វាភ្លេចភ្លាំងយូរយាមកហើយនេះ រកឆ្លើយចំពោះសំណួរ -- ខ្ញុំក្លាប់មិនបានទេព្រោះអីវាយូរពេកហើយ។

**ស៖** ម្សិលមិញលោកសាក្សីលោកបាននិយាយសំដៅលើបុគ្គលម្នាក់ឈ្មោះថាតាម៉ុក។ តើលោកនៅចាំអ្វីខ្លះអំពី តាម៉ុក នេះ?

**ឆ៖** តាម៉ុក ដូចខ្ញុំបានរាប់រៀបខាងដើមថាគាត់ជាយោធា, ចាន់ ស៊ី ខាងផ្នែនយោបាយ។ ការសិក្សារៀនសូត្រកម្មាភិបាលគ្រប់តំបន់គ្រប់ឃុំដែលយកទៅប្រជុំសិក្សារៀនសូត្រ។

**ស៖** ខ្ញុំចង់សួរលោកថាតើចំពោះ តាម៉ុក នេះលោកនឹកឃើញយ៉ាងម៉េចខ្លះអំពីគាត់? ខ្ញុំចង់សួរអំពីគាត់ទេ តើលោកធ្លាប់ជួបនិយាយជាមួយគាត់ដោយផ្ទាល់ទេ?

[០៩:១៦:៥៥]

**ឆ៖** មិនដែលជួបផ្ទាល់ទេនៅក្នុងការសិក្សារៀនសូត្របានឃើញ គាត់បង្រៀនទូវកម្មាភិបាលឃុំស្រុកតំបន់។

**ស៖** សូមជម្រាបខ្ញុំបើសិនខ្ញុំនិយាយខុស។ ពេលម្តងនោះដែលលោកឃើញ តាម៉ុក នោះបានន័យថានៅពេលដែលលោកនៅជាមួយកម្មាភិបាល១៥០, ២៥០នាក់ ឬ៣៥០នាក់នោះ តើអ៊ីចឹងដែរឬទេនៅពេលនោះហើយដែលលោកឃើញ តាម៉ុក?

**ឆ៖** ត្រង់ហ្នឹងខ្ញុំបានឃើញ តាម៉ុក ការបង្រៀនសិក្សារៀនសូត្រកម្មាភិបាល។

**ស៖** កាលពីម្សិលមិញលោកសាក្សីលោកបានផ្តល់សក្ខីកម្មឬឆ្លើយថា តាម៉ុក -- ខ្ញុំសូមដកស្រង់ពាក្យសម្តីរបស់លោកគឺតាមនយោបាយនៃគ្រប់គ្រងការងារនយោបាយនោះ តាម៉ុក នេះគឺថានៅពីលើ ជូ ជេត។ បាទគឺ តាម៉ុក នេះនៅក្រោមបើតាមន័យនយោបាយគឺគាត់នៅក្រោម ជូ ជេត ទេ។ តើលោកមានន័យយ៉ាងម៉េចដែរ ដែលថា តាម៉ុក ការងារនយោបាយក្រោម ជូ ជេត នេះ?

**ឆ៖** ជូ ជេត ដែលគាត់ខាងផ្នែកនយោបាយខ្លាំងលើ តាម៉ុក ចលនាប្រជាជន ដឹកនាំឲ្យកម្មាភិបាលចលនាងើបក្រោកឡើងតស៊ូ ហ្នឹងចំពោះ ជូ ជេត។ កាលនោះគាត់ខ្លាំងលើ តាម៉ុក ខ្លាំងខាងផ្នែកនយោបាយបំផុសប្រជាជនឲ្យចូលតស៊ូធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិ។

[០៩:១៩:៥៤]

**ស៖** តើលោកអាចជម្រាបជូនយើងខ្ញុំដែរឬទេ តើឋានៈខាងនយោបាយ ឬក៏ខ្ញុំប្រើពាក្យបច្ចេក-ទេសថាឋានានុក្រមនេះ គឺយ៉ាងម៉េច បានន័យថា តាម៉ុក នៅពីលើ ជូ ជេត ឬក៏ ជូ ជេត នេះ នៅពីលើ តាម៉ុក បើសិនជាយើងប្រៀបធៀបពីតួនាទីឋានៈនោះ?

**ឆ៖** ក្រោយមកទៀត តាម៉ុក ដែលចលនាប្រជាជនឲ្យធ្វើយោធា, ក្រោយមកបាន តាម៉ុក ជាអ្នកយោធាហ្នឹងវាខ្លាំង វាខ្លាំងខាងធ្វើសង្គ្រាម កាន់កងទ័ព ក្រោយមកហ្នឹង។ ដែលគាត់ប្រមូលផ្តុំយុវជន យុវនារី ដើម្បីឃោសនាចូលរួមចំណែកកាន់អាវុធ។ អ៊ីចឹងខាង ចាន់ ស៊ី គាត់ខាងផ្នែកនយោបាយ វាខ្សោយ វាអត់អាវុធ។ អ៊ីចឹងទេ គ្រាន់តែការបំផុសចលនាប្រជាជនឃើញថា ប្រជាជនចូលរួម កម្មាភិ-បាលចូលរួម តែដោយឡែក តាម៉ុក គាត់កាន់យោធា មានអាវុធ។ អ៊ីចឹងទេ ក្រោយឡើងដែលទ័ពដែលបានចូលរួមជាមួយគាត់ហ្នឹង គឺដោយសារ ចាន់ ស៊ី ដែរ។ សូមអស់ប៉ុណ្ណឹង។

[០៩:២១:៣៩]

**ស៖** ខ្ញុំសួរលោកអ៊ីចេះទេ លោកសាក្សី តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តាម៉ុក នេះ បើនិយាយពីតួនាទីនេះ ធំជាង ជូ ជេត ឬក៏យ៉ាងម៉េច ប្រសិនបើលោកដឹង?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំ ក្រោយមកខ្ញុំមិនបានដឹងទេ។ ខ្ញុំអត់បានដឹងទេ។ បើខាងយោធា បើតាមទៅមានប្រៀប តាម៉ុក មានប្រៀបលើអ្នកនយោបាយ គាត់ក្តាប់បានកងទ័ព។ អ៊ីចឹងបានន័យថា សន្និដ្ឋានទេ ខ្ញុំថាអ្នកខាងផ្នែកយោធាគឺខ្លាំង។ អ្នកនយោបាយគឺគ្រាន់តែបំផុសចលនាឲ្យប្រជាជនក្រោកឡើងតស៊ូ។ ចលនាតាំងពីយុវជន តាំងពីយុវនារី ចូលរួមធ្វើទ័ព។ ហ្នឹងខាងនយោបាយ។ ប្រមូលចេញពីនយោបាយ របស់ តាស៊ី ដែលគាត់បំផុសចលនាហ្នឹង ទ័ពក៏ត្រូវចូលខាងផ្នែកយោធា។ អ៊ីចឹងបានន័យថា ខ្ញុំក្តាប់មិនបានដែរ ត្រង់ខ្លាំងខាងនយោបាយ ឬក៏កងទ័ពខ្លាំង -- អ៎! តាម៉ុក ខ្លាំងជាង ឬក៏ តាស៊ី ខ្លាំងជាង ខ្ញុំក្តាប់មិនបានដែរទេ ត្រង់ហ្នឹង កន្លងមក ត្បិតអីគាត់កាន់នៅភូមិនិរតី--

**ស៖** សូមអធ្យាស្រ័យលោក។ សាក្សី ខ្ញុំសូមសួរផ្តោតសំណួររបស់ខ្ញុំ។ តើលោកដឹងតួនាទីរបស់តាម៉ុក និង ជូ ជេត ទេ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥?

[០៩:២៤:១២]

**ឆ៖** ខ្ញុំអត់បានដឹងទេត្រង់ហ្នឹង ៧៥ហ្នឹង។ ខ្ញុំជាថ្នាក់ឃុំ មិនអាចក្តាប់ដល់រហូតយោធា បើនយោបាយ គាត់ហៅទៅរៀន ហ្នឹង ចាន់ ស៊ី។ ដល់បានកងទ័ពច្រើនមក ខាងក្រោយមក ខ្ញុំក្តាប់អត់បានដែរត្រង់ហ្នឹង។ ប្រហែលជាអ្នកមានដែលមានអំណាចខាងផ្នែកយោធា ពិតជាខ្លាំងជាងអ្នកនយោបាយ។

**សៈ** ខ្ញុំសូមអនុញ្ញាតសួរលោកបន្ថែមទៀត។ លោកគ្រាន់តែប្រាប់យើងខ្ញុំអ្វីដែលលោកបានដឹងតែប៉ុណ្ណោះ លោកមិនប្រាកដនោះទេ។ ខ្ញុំសូមនិយាយត្រឡប់ទៅវគ្គអប់រំនយោបាយ វគ្គអប់រំវិញ ដែលលោកលើកឡើងថានៅពេលនុ៎ងគឺ តាម៉ុក និង ជូ ជេត ក៏ចូលរួមផងដែរ។ កាលពីម្សិលមិញនោះគឺថាលោកបានលើកឡើងអំពី តាម៉ុក ហើយនិង ជូ ជេត នោះគឺមានការយល់ឃើញផ្ទុយគ្នា បានន័យថាគាត់ប្រឆាំងគ្នា។ តើលោកបានដឹងអ្វីបន្ថែមទៀតទេ ចំពោះអ្នកទាំងពីរហ្នឹងដែលគាត់ខ្វែងយោបល់គ្នា គាត់ជំទាស់គ្នានៅពេលនោះ?

**ឆៈ** ត្រង់ហ្នឹងខ្ញុំអត់បានដឹងទេត្រង់ហ្នឹង កន្លែងដូចថាវា មួយយោធា មួយនយោបាយ ហើយគាត់ដែលទៅ--

[០៩:២៦:២៦]

**សៈ** ខ្ញុំសូមរំឭកលោកឡើងវិញ។ កាលពីម្សិលមិញលោកនិយាយថា មានការយល់ឃើញខុសគ្នាអំពីការផែនការជម្លៀសភ្នំពេញនោះ គឺអ្នកទាំងអស់នោះមានការយល់ឃើញខុសគ្នា។ តើលោកនៅនឹកឃើញទេ? លោកអាចរៀបរាប់បានទេ?

**ឆៈ** មានការជម្លៀសប្រជាជនដែលកងទ័ពខាងនិរតី ដែលត្រូវលើកឡើង តែវ៉ៃត្រូវតែជម្លៀសជម្លៀសប្រជាជន វ៉ៃកន្លែងណាក៏ជម្លៀសប្រជាជនកន្លែងនុ៎ង ហើយជម្លៀសបើចាប់ឈ្លើយសឹកក៏យកមក ទាំងយោធា ខាងទាហាន ទាំងប្រជាជន អូសយកមក មកខាង គេហៅថាដីរំដោះ។

**សៈ** ខ្ញុំសួរអំពីវគ្គរៀនសូត្រឡើងវិញ។ លោកបានលើកអំពីវគ្គអប់រំនយោបាយនេះ តើគេអប់រំហ្នឹងនៅក្នុងឆ្នាំ៧៣ ឬក៏៧៤? លោកអាចបញ្ជាក់បានដែរទេ? ហើយក្នុងខែណាដែរបើសិនជាលោកចាំជាក់លាក់នោះ?

**ឆៈ** ហ្នឹងខ្ញុំអត់ចាំទេ វាអត់បានចាំ។ ឆ្នាំខែខ្ញុំអត់បានចាំ វាកន្លងផុតយូរយារហើយរកនឹកមិនឃើញទេ។ សូម្បីតែឈ្មោះអ្នកដែលបានទៅរៀនសូត្រស្គាល់គ្នាក៏ខ្ញុំភ្លេចដែរ មិនដឹងជាឈ្មោះអីទៀត។

[០៩:២៨:៤៤]

**សៈ** លោកសាក្សីសូមឲ្យលោកព្យាយាមស្មានមើលតើនៅក្នុងឆ្នាំណាដែរ? ការអប់រំនោះ២ឆ្នាំមុនរំដោះទីក្រុងភ្នំពេញ ឬក៏១ឆ្នាំមុនពេលរំដោះភ្នំពេញ តើលោកអាចនឹកឃើញ គិតស្មានមើលក្នុងចន្លោះពេលហ្នឹងឬក៏យ៉ាងណា?

**ឆៈ** រឿងស្មានមិនទាន់ជម្លៀសប្រជាជននៅឡើយទេ ហ្នឹងដែលខ្ញុំថាស្មាន ប៉ុន្តែដល់ពាក្យស្មាន

ហ្នឹងវាអត់ដូចថាវាមិនត្រឹមត្រូវដែរ។ ហើយស្មានទៅវា -- មានការភ្លេចភ្លាំងទៅ ស្មានទៀតវាទៅមិនរួចទេ ខ្ញុំអត់ប៊ានស្មាន។

**ស៖** នៅពេល តាម៉ុក និយាយអំពីការជម្លៀសប្រជាជនទីក្រុងភ្នំពេញ តើគាត់អះអាងយ៉ាងម៉េចដែរនៅពេលនោះ? តើគាត់នឹងនិយាយពីលទ្ធភាពជម្លៀសហ្នឹងយ៉ាងម៉េចដែរ? គាត់អះអាងយ៉ាងម៉េចដែរអំពីផែនការជម្លៀសប្រជាជនទីក្រុងភ្នំពេញ?

**ឆ៖** គាត់អះអាងរឿងកងទ័ពជុំវិញដែលត្រូវ ដែលគាត់អះអាងថា "យើងមានជ័យជម្នះហើយនៅខាងបូព៌ា និរតី ពាយ័ព្យ ទ័ពដែលច្រើនវាគ្រប់គ្រងទ័ពហ្នឹង ថាយើងត្រូវវាយលុកទីក្រុងភ្នំពេញលុះត្រាណាតែបាន"។

[០៩:៣១:០៥]

**ស៖** ខ្ញុំយល់អ្វីដែលលោកលើកឡើង ក៏ប៉ុន្តែខ្ញុំចង់ដឹងថានៅពេលនោះ តាម៉ុក ពន្យល់ហេតុផលយ៉ាងម៉េចទៅខាងយោធានោះ ថាត្រូវតែជម្លៀសប្រជាជនទីក្រុងភ្នំពេញ? តើហេតុផលហ្នឹង វិធានការហ្នឹងគេធ្វើយ៉ាងម៉េច? គាត់ពន្យល់ហ្នឹងឲ្យហេតុផលយ៉ាងម៉េចទើបចង់មានការជម្លៀសទីក្រុងភ្នំពេញនោះ? តើលោកដឹងទេ ចាំទេ?

**ឆ៖** ចាំហើយ ព្រោះខ្ញុំអត់យល់ដែរត្រង់ហ្នឹងៗហើយ ត្បិតអីគាត់ខាងយោធា ដូចថាព័ទ្ធទីក្រុងភ្នំពេញគ្រប់ទិសតំបន់ហើយ ខ្ញុំក្តាប់មិនបានដែរទេត្រង់ហ្នឹង។ ដែលគាត់លើកគោលការណ៍ឡើងថា "យើងត្រូវតែសម្រុកវ៉ៃទីក្រុងភ្នំពេញ ជម្លៀសប្រជាជនចេញមក។ អានេះជានយោបាយមួយគឺថាយើងត្រូវតែឈ្នះ វ៉ៃទាល់តែបាន ត្បិតអីកងទ័ពយើងមានការគ្រប់គ្រាន់"។ នេះដែលខ្ញុំឮចេញពីប្រជុំកម្មាភិបាលខាងយោធា។ ខ្ញុំមិនមែនជាខាងយោធាទេ នៅក្នុងថ្នាក់ឃុំ បាទសមាជិកឃុំ។ ចប់ប៉ុណ្ណឹងហើយ។

**ស៖** តើលោកនៅចាំទេនៅពេលវគ្គអប់រំនយោបាយនោះ នៅក្នុងវគ្គអប់រំនយោបាយនោះ គឺគេក៏បានពិភាក្សាលើកឡើងអំពីការទម្លាក់គ្រាប់បែកបេ៥២ផងដែរ តើលោកចាំទេថាគេបានពិភាក្សាចំណុចហ្នឹងដែរ?

[០៩:៣៣:១៥]

**ឆ៖** ជំនាន់ដែលទម្លាក់គ្រាប់បែក កាលនោះនៅវៀតណាម នៅឡាវ កម្ពុជា។ គេឲ្យកម្ពុជាទៅចរចាដើម្បីស្វែងរកសន្តិភាពឲ្យប្រជាជន តែដោយឡែកខាងយោធា ម៉ុក នេះ គាត់ថា--

**ស៖** ខ្ញុំសូមស្កាត់សម្តីលោក ខ្ញុំមិនមានពេលវេលាច្រើននោះទេ។ ក្នុងវគ្គអប់រំនយោបាយនោះ

ខ្ញុំគ្រាន់តែចង់សួរថា តើគេមានបានពិភាក្សាលើកឡើងអំពីការទម្លាក់គ្រាប់បែកពីពួកចក្រពត្តិទេ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំដូចជាវាភ្លេចភ្លាំងទៅហើយ។

**ស៖** តើលោកនៅចាំទេ ថានៅពេលនោះ តាម៉ុក មាននិយាយអំពីស្ថានភាពជនភៀសខ្លួននៅក្នុងទីក្រុងភ្នំពេញ ឬក៏លើកឡើងអំពីបញ្ហាខ្វះម្ហូបអាហារនៅក្នុងទីក្រុងភ្នំពេញទេ?

**ឆ៖** ខ្ញុំកន្លែងហ្នឹង រឿងទីក្រុងខ្វះខាតស្បៀងអាហារ ខ្ញុំអត់ក្ដាប់អត់បានទេ អារឿងនយោបាយខាងយោធា។ ខ្ញុំជាមូលដ្ឋាននៅថ្នាក់ឃុំឲ្យស៊ីជម្រៅតាមដាន ដល់រហូតយោធាទៀត រូបខ្ញុំក្ដាប់មិនបានដែរកន្លែងហ្នឹង។

**ស៖** លោកសាក្សី តើលោកវាអាចដែរឬទេដែលថា តាម៉ុក ហើយនិង ជូ ជេត មិនដែលនិយាយអំពីផែនការជម្លៀសទីក្រុងភ្នំពេញ អាចថាលោកចាំច្រឡំ ឬក៏លោកស្ដាប់ច្រឡំយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:៣៦:០៥]

**លោក ឃីត សេយ្យន័រ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរបែបនេះ ព្រោះសំណួរបែបនេះវាជាការស្នើឲ្យសាក្សីធ្វើការប៉ាន់ស្មាន។ សាក្សីគឺគាត់មានសិទ្ធិផ្ដល់ភស្តុតាងតែទៅលើអ្វីដែលគាត់បានដឹង បានឮ បានឃើញ។ ដូច្នេះការសួរសំណួរបែបហ្នឹងគឺវាហាក់ដូចជាការធ្វើឲ្យសាក្សីបំពេញតួនាទីលើសពីអ្វីដែលគាត់គួរតែធ្វើ។ ដូច្នេះវាមិនអាចនោះទេ ដែលថាវាពាក់ព័ន្ធទៅនឹងរឿងបញ្ហា ជូ ជេត និង តាម៉ុក គឺវាទូលំទូលាយពេក ហើយវាជាការប៉ាន់ស្មាន ឬក៏ទាយស្មានផង។ សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមានលក្ខណៈមួយ គឺថាខ្ញុំសួរសំណួរទៅលើសាក្សីហ្នឹងក្នុងលក្ខណៈងាយស្រួល។ អាចបានន័យថា ខ្ញុំគ្រាន់តែលើកឡើងថាគាត់អាចចាំច្រឡំ ឬក៏គាត់យល់ច្រឡំដែលថាមានការប្រជុំ ប៉ុន្តែវាមិនមានការប្រជុំនោះ។ វាគឺថាខ្ញុំគ្រាន់តែព្យាយាមសួរសំណួរឲ្យបានសុភាព ឲ្យបានល្អ មិនដូចខាងព្រះរាជអាជ្ញានោះទេ។ ដូច្នេះខ្ញុំគិតថា ខ្ញុំគ្រាន់តែលើកឡើងពីលទ្ធភាពដែលថាគាត់អាចចាំច្រឡំ ឬក៏គាត់យល់ច្រឡំ។ ហើយខ្ញុំគិតថា ខ្ញុំគួរតែអនុញ្ញាតឲ្យសួរសំណួរបែបនេះបាន។ សូមអរគុណលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៨:៣០]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីការពារក្តីលោក នួន ជា ចំពោះសាក្សី គឺមិនមានមូលដ្ឋានសមស្របទេ។ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្តីលោក នួន ជា នៅសំណួរចុងក្រោយនេះ។ ប្រសិនបើលោកមិនចងចាំទេ គឺសូមលោកមេធាវីការពារក្តីតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត ដើម្បីឲ្យសាក្សីចងចាំ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមសួរសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើវាអាចដែរឬទេដែលថាលោកចាំខុស គឺថាមិនមានការពិភាក្សានៅក្នុងកិច្ចប្រជុំរវាង តាម៉ុក និង ជូ ជេត អំពីការជម្លៀសភ្នំពេញ។ តើវាអាចដែរឬទេដែលគ្មានការប្រជុំហ្នឹងហើយលោកចាំខុសទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំមិនបានចាំទេនៅក្នុងពេលនោះ ត្បិតអីវាឋានៈខ្ញុំវាជាសមាជិកឃុំ ហើយការដឹង ការយល់ហ្នឹងទាល់តែខាងទៅរៀនជានយោបាយអី អាហ្នឹងបានៗទៅ។ ត្រង់ឲ្យដឹងថា ពីរនាក់ ចាន់ ស៊ី និង តាម៉ុក ហ្នឹង ដោយវាប្រេះឆាយ៉ាងម៉េច ហើយគោលការណ៍ដែលត្រូវជម្លៀសប្រជាជនហ្នឹងចេញពីទីក្រុងភ្នំពេញហ្នឹង ក៏ខ្ញុំមិនបានស៊ីជម្រៅដល់ការយល់ដឹងរបស់ខ្ញុំដែរ។ ខ្ញុំបើគេហៅទៅប្រជុំនៅក្នុងការដឹកនាំរបស់ តាស៊ី អាហ្នឹងខ្ញុំបានទៅ។ ហើយតាម៉ុក គាត់អ្នកខាងយោធា។ ដោយឡែកមិនដាច់ពីនយោបាយទេ ពាក់ព័ន្ធជាមួយ តាស៊ី និង តាម៉ុក ហ្នឹង។ ហ្នឹងខ្ញុំថា -- គេថាអង្គការលើ។ អង្គការលើហ្នឹងស្គាល់តែឈ្មោះថាអង្គការលើ។ រួចខ្ញុំមិនយល់ដែរទេកាលហ្នឹង អង្គការលើៗ។ ខ្ញុំមានតែប៉ុណ្ណឹង។ វាបាត់បង់--

[០៩:៤១:៣២]

**ស៖** សូមអរគុណលោកសាក្សី សូមអរគុណ។ ឥឡូវនេះខ្ញុំសូមបន្តទៅមុខទៀត។ កាលពីម្សិលមិញលោកបាននិយាយអំពី ហ៊ូ នឹម។ តើលោកស្គាល់ ហ៊ូនឹម ផ្ទាល់តែម្តង ស្គាល់គាត់ជាលក្ខណៈបុគ្គល

ឬក៏មិនទេ? ឬក៏គ្រាន់តែធ្លាប់ឮឈ្មោះ?

**ឆ៖** ខ្ញុំអត់បានស្គាល់ទេ ហ៊ូ នឹម ហើយនិង ខៀវ សំផន ខ្ញុំមិនដែលស្គាល់។ តែ ហ៊ូ យន់ គាត់ប្រមូលកម្មាភិបាលទៅធ្វើសន្និបាតនៅតាំងពោធិ៍ ដូចខ្ញុំបានរាប់រៀបហើយ។ តែគ្រាន់តែខ្ញុំ គ្រាន់តែឃើញពីចម្ងាយទេ មិនបានទៅដល់ទេ។ លើកឡើងអំពីជម្លៀសប្រជាជន។ គាត់ត្រូវប្រឆាំង មិនឱ្យជម្លៀសប្រជាជនទេ។ ហ្នឹងចំពោះ ហ៊ូ យន់ ដែលខ្ញុំបានទៅជួបហើយសិក្សាគាត់ដឹកនាំនៅក្នុងវត្តតាំងពោធិ៍ហ្នឹងស្រុកថ្ពង ខ្ញុំបានដឹងប៉ុណ្ណឹង។ រួចក្រោយមកទៀតលែងឮឈ្មោះបោះសំឡេង វាបាត់ឈឹងទៅ--

**ស៖** លោកសាក្សីសូមអភ័យទោសលោកសាក្សី ខ្ញុំសូមទោសដែលខ្ញុំកាត់លោក។ ការពិត ខ្ញុំចង់សួរពី ហ៊ូ នឹម អំមិញលោកនិយាយពីហ៊ូ យន់។ ប៉ុន្តែលោកបានផ្តល់ចម្លើយថា លោកមិនស្គាល់ ហ៊ូ នឹម ទេ។ ហើយលោកក៏បានឆ្លើយផងដែរថាលោកគិតថា ហ៊ូ នឹម ហ្នឹង -- គឺថាលោកថា ហ៊ូ នឹម ហើយនិង ខៀវ សំផន ដូចជា ខៀវ សំផន ដែរគឺប្រឆាំងទៅនឹងការជម្លៀសទីក្រុងភ្នំពេញ។ អ៊ីចឹងមែនទេ?

[០៩:៤៣:៤៩]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធានខ្ញុំសូមកាត់ គឺថាមិនមានភស្តុតាងពីសាក្សីនេះដែលនិយាយថា ហ៊ូ នឹម ប្រឆាំងនឹងការជម្លៀសនោះទេ។ ដូច្នេះខ្ញុំធ្វើការជំទាស់នេះដើម្បីជាប្រយោជន៍ប្រតិចារឹក គឺថាការនិយាយអំពី ហ៊ូ នឹម គឺថានៅពេលដែលខ្ញុំធ្វើការអាននូវសម្រង់អំពីអត្ថបទមួយខ្ញុំសូមបង្ហាញអំពីទំព័រ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

តើលោកចង់និយាយទំព័រ0041958។ ប្រសិនបើអ៊ីចឹងខ្ញុំសូមកែរសំណួរខ្ញុំឡើងវិញលោកសាក្សី។

**ស៖** នៅក្នុងរបាយការណ៍របស់ ប៉ែន យៀរនិន គឺការសម្ភាសរបស់ ប៉ែន យៀរនិន ជាមួយនឹងលោកសាក្សីនោះគឺវាហាក់ដូចជាថាលោកបានប្រាប់លោក ប៉ែន យៀរនិន ថា ហ៊ូ នឹម ប្រឆាំងជំទាស់ទៅនឹងការជម្លៀសទីក្រុងភ្នំពេញ។ តើលោកចាំថាលោកបាននិយាយអំពីការដែលថា ហ៊ូ នឹម ប្រឆាំងជំទាស់ទៅនឹងការជម្លៀសទីក្រុងភ្នំពេញ។ តើលោកចាំថាលោកបាននិយាយអំពីការដែលថា ហ៊ូ នឹម ជំទាស់ទៅនឹងការជម្លៀសហ្នឹង ប្រាប់ ប៉ែន យៀរនិន ដែរឬទេ?

[០៩:៤៥:១០]

**ឆ៖** ខ្ញុំអត់បានប្រាប់ទេ, ប្រាប់តែ ហ៊ូ យន់ ដែលបានទៅជួបធ្វើមហាសន្និបាតនៅវត្តតាំងពោធិ៍ ខៀវ សំផន ក៏ខ្ញុំអត់ស្គាល់គាត់។ ហ៊ូ នឹម ក៏អត់ ឃើញតែ ហ៊ូ យន់ ម្នាក់ដែលត្រូវប្រមូលកម្មាភិបាល

ទៅធ្វើមហាសន្និបាតនៅវត្តតាំងពោធិ៍ ស្រុកថ្កូង។ ហើយខ្ញុំនៅពីចម្ងាយទៀត នៅឆ្ងាយ។ អានេះវាច្រើននៅក្នុងវត្ត វាពេញវត្តដែរហើយ។ ខ្ញុំស្គាល់ -- គ្រាន់តែឮតែឈ្មោះទេ បើ ហ៊ូ យន់ បានមើលពីឆ្ងាយទៅតែការចងចាំ វាបាត់បង់ មកទល់ដែលបានជួបគ្នានោះ តែម្តងទេ។

**ស៖** លោកសាក្សីតើលោកចង់និយាយ ឬក៏ចង់មានន័យថា លោកមិនដែលនិយាយជាមួយនឹងប៉ែន យៀរនិន អំពី ហ៊ូ នឹម ដោយសារតែលោកមិនស្គាល់ ហ៊ូ នឹម។ តើខ្ញុំនិយាយអ៊ីចឹង តើជាការត្រឹមត្រូវដែរឬទេ?

[០៩:៤៦:៤៥]

**ធ៖** ខ្ញុំត្រង់ណាដែលខ្ញុំដឹង ខ្ញុំជម្រាបជូនថាខ្ញុំដឹង ថាខ្ញុំស្គាល់។ បើគ្រាន់តែឮតែឈ្មោះ មុខមិនស្គាល់ រូបមិនស្គាល់ ខ្ញុំឮតែតាមគេនិយាយដែរ តាមគេនិយាយថា មាន ហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន គាត់ចេញពីទីក្រុងភ្នំពេញមក ប៉ុណ្ណឹងខ្ញុំដែលដឹង។ ហើយ ហ៊ូ យន់ ហ្នឹង ដែលគាត់ធ្វើមហាសន្និបាតប្រមូលកម្មាភិបាល មានប្រជាជនចូលរួម ប្រកាសថា៖ "យើងបើសិនជាវ៉ៃបែកទីក្រុងភ្នំពេញ យើងមិនបាច់ជម្លៀសប្រជាជនទេ។ ទុកប្រជាជននៅក្រុង ហើយនិងប្រជាជនដែលយើងនៅនេះ ដើម្បីវាងាយស្រួល មិនឲ្យពិបាកច្របូកច្របល់"។

**ស៖** លោកសាក្សីៗសូមអភ័យទោស។ សូមអរគុណលោកសាក្សី។ ដូចដែលខ្ញុំចង់និយាយអ៊ីចឹង សំណួររបស់ខ្ញុំទាក់ទងទៅនឹង ហ៊ូ នឹម។ ឥឡូវនេះ ខ្ញុំសួរឡើងវិញ តើខ្ញុំអាចនិយាយថា លោកអត់ដឹងអ្វីទាំងអស់អំពី ហ៊ូ នឹម។ ថាតើ ហ៊ូ នឹម គាត់គាំទ្រ ឬក៏ប្រឆាំងទៅនឹងការជម្លៀស តើវាអាចដែរទេ ដែលថាលោកអត់ដឹងសោះ ថាតើ ហ៊ូ នឹម គាត់គាំទ្រ ឬក៏គាត់ប្រឆាំង គឺអត់ដឹងទេ?

**ធ៖** ខ្ញុំអត់បានដឹងទេ។ ដោយ ហ៊ូ នឹម ខ្ញុំអត់ដឹង។

[០៩:៤៨:៤៦]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ គឺថាខ្ញុំទុកឱកាសឲ្យសហការីខ្ញុំគាត់សួរអំពី ហ៊ូ យន់ ហើយនិង ខៀវ សំផន។ ឥឡូវនេះ ខ្ញុំសួរសំណួរផ្សេងមួយទៀត កាលពីម្សិលមិញ លោកបាននិយាយអំពី គឺថាទាហានលន់ នល់ ប្រហែលជា១០០នាក់ ឬក៏១០០នាក់ជាងនោះ ដែលគេយកមកពីភ្នំពេញ ហើយគេយកមកទុកនៅក្បែរវត្តមួយ។ តើលោកចាំថាកាលពីម្សិលមិញ លោកបានឆ្លើយអំពីបញ្ហាទាហាន លន់ នល់ ជាង១០០នាក់ដែលគេយកមកដាក់នៅជិតវត្តហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំដឹងអាហ្នឹង។ គឺខ្ញុំបាននៅហ្នឹងដែរ នៅទាហានហ្នឹង មានគេជម្លៀសពីទីក្រុងភ្នំពេញមកៗដាក់នៅខាងត្បូងវត្តព្រៃជុំហ្នឹងតែម្តង។ ហើយសួរថាចុះហេតុអីដែលស្គាល់កងទ័ព? កងទ័ពសម្គាល់ថា មានសាក់កាដូ តែចំពោះអាវុធអត់មានទេ។ តែបាននៅតែ១យប់១ថ្ងៃទេ គេបញ្ជូនទៅលិចបាត់ទៀត គេថាឲ្យទៅរៀន។ ខ្ញុំបានដឹងតែប៉ុណ្ណឹងទេ ឲ្យហួសពីហ្នឹងគឺខ្ញុំអត់ដឹង។ ទៅអង្គការលើៗ ឲ្យរៀនបន្តទៀត បានឲ្យធ្វើយោធា ហើយវាបាត់ឈឹងទៅ ហើយខ្ញុំបានដឹងឯណាបើឃើញតែមួយពេលហ្នឹង គេបញ្ជូនទៅបាត់ទៀតទៅ។ តែគ្រាន់តែស្មានថា វាចូលរយដែរដែលជម្លៀសទៅហ្នឹង។ បើចុះ ចុះបន្តិចបន្តួចក្រោមរយហ្នឹង តែបើថាទេខ្ញុំចេះតែថាចេះនិយាយ សូមឲ្យទៅពិនិត្យសង្កេតសួរប្រជាជននៅជុំវិញវត្តហ្នឹង ទោះបីយ៉ាងម៉េចក៏គាត់ឆ្លើយថាទាហានដែរបាទ។ ខ្ញុំអស់ប៉ុណ្ណឹង។

[០៩:៥១:៥០]

**ស៖** លោកសាក្សី ឥឡូវនេះយើងទុកម្តុំសិន។ តើលោកចាំដែរឬទេថា លោកខ្លួនលោកផ្ទាល់បាននិយាយជាមួយនឹងអតីតទាហាន លន់ នល់ ហ្នឹងជាង១០០នាក់ហ្នឹង។ តើលោកធ្លាប់បានជជែកជាមួយពួកគាត់នោះដែរឬទេ?

**ឆ៖** អត់បានទេត្រង់ហ្នឹង ខ្ញុំអត់បាន ព្រោះអីខ្ញុំឈឺ ហើយគេប្រាប់ខ្ញុំថា "អ្ហ៎ក!ទាហានមកច្រើនណាស់ គេជម្លៀសមក" ហើយខ្ញុំដេកពេទ្យចាក់ថ្នាំនៅក្នុងវត្តហ្នឹង ដែលគេជម្លៀសប្រជាជនមកនៅក្នុងវត្តព្រៃជុំ មួយជួរហ្នឹងសុទ្ធតែប្រជាជនហើយនិងកងទ័ពដែលគេជម្លៀសមក។ ហើយជួយផ្តល់នូវស្បៀងអាហារ ឲ្យប្រជាជនឧបត្ថម្ភ។ ហើយមកហ្នឹងប្រជាជនខ្លះដើរ ខ្លះរ៉ែកកូន ខ្លះអូសរទេះ រួចខ្លះមានម៉ូតូហើយម៉ូតូនុំងមកឃាត់ត្រង់កន្លែងមួយកន្លែង ក្រាំងចេក – វត្តក្រាំងចេក, មួយកន្លែងទៀតនៅព្រៃជុំគឺគេទុក ទុកហ្នឹង ថាឲ្យយកទៅទៀតគឺអត់ទេ ទាំងឡាន ទាំងម៉ូតូ។ រួចពេលនោះកាលដែលជម្លៀសនោះវាខែវាចុងខែពិសាខចុះ ខ្ញុំមិនដឹង ថាខែពិសាខចុះ គេជម្លៀស។

[០៩:៥៣:១៧]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះយើងនិយាយអំពីទាហាន លន់ នល់ ជាង១០០នាក់នោះ។ លោកបាននិយាយថាលោកមិនបានជួបនិយាយជាមួយពួកគាត់ទេ គឺលោកឮអ្នកដទៃប្រាប់លោកហើយអ្នកដទៃនោះប្រហែលជាបាននិយាយជាមួយពួកទាហាននោះ។ តើអ្នកដែលប្រាប់លោកថាទាហានហ្នឹងមកពីភ្នំពេញហ្នឹង គេមានប្រាប់លោកទេថា ហេតុអីបានជាគេដឹងថាពួកទាហានហ្នឹងគេយកមកពីភ្នំពេញ។ តើគេមានប្រាប់លោកទេ?

**ឆ៖** តាមជម្លៀសតាមខ្សែៗណាដែលត្រូវគេបញ្ជូន។ ផ្លូវដែលត្រូវបញ្ជូន ខាងត្បូងវត្តព្រៃជុំ។ ហើយប្រជាជនហ្នឹងហើយប្រជាជន ពិសេសគាត់អ្នកជួយឧបត្ថម្ភបាយយកទៅឲ្យទាហានហូបហ្នឹងពេលល្ងាច។ ព្រឹកឡើងគេបញ្ជូនទៅ ទៅរៀនសូត្រទៅបាត់ ទៅលើទៅ ទៅលើ។ ហ្នឹងដែលខ្ញុំបានដឹងហើយក៏ខ្ញុំវាកៀកដែរត្រពាំងទឹកហ្នឹង វាដីប្រហែលខ្ទង់១០០ម៉ែត្រ ជាង១០០បន្តិចបាទ។ រួចខ្ញុំវាមានអាការៈរោគហ្នឹង ក្អកផ្ដាក់ឈាម។ ម្យ៉ាងគេមិនឲ្យខ្ញុំ គឺថានៅឲ្យស្ងៀម ថានៅឲ្យស្ងៀម ដេកតែចាក់ថ្នាំទៅ ក្រែងលោកវាជរ។ តែគ្រាន់តែខ្ញុំទៅឃើញដែរ ឃើញហ្នឹងឃើញវាមិនជាសួរនាំមកពីនេះមកពីនោះអត់មានទេ ខ្ញុំគ្រាន់តែឃើញគេងូតទឹក ថាមួយក្រុមនេះជាក្រុមទាហាន លន់ នល់។ រួចផែនការរបស់គេហ្នឹង គេថាទៅបង្រៀននៅខាងលើដើម្បីយើងវ៉ៃតទៅទៀត។ បាទ អានេះទិសដៅរបស់គេហ្នឹងគឺអ៊ីចឹង។ រួចទៅមិនដឹងជាទៅណា គេថាទៅលើៗទៅរៀនសូត្រ ខ្ញុំក្ដាប់មិនបានដែរទេ។ សូមមានតែប៉ុណ្ណឹង។

[០៩:៥៥:៥៤]

**ស៖** សំណួររបស់ខ្ញុំគឺថា ចង់សួរលោកអ៊ីចេះទេ តើអ្នកដែលប្រាប់លោកថា ទាហាន លន់ នល់ហ្នឹងគេយកមកពីភ្នំពេញ។ គឺខ្ញុំចង់ដឹងថា តើអ្នកដែលប្រាប់លោកហ្នឹង គេធ្វើម៉េចបានដឹងទាហានហ្នឹងមកពីភ្នំពេញ? តើអ្នកដែលគេប្រាប់លោកហ្នឹង គេបាននិយាយជាមួយពួកទាហាន លន់ នល់ហ្នឹង ឬមួយក៏យ៉ាងម៉េច? ខ្ញុំចង់ឲ្យលោកប្រាប់ថាហេតុអ្វីបានជាគេដឹងថាទាហានហ្នឹងមកពីភ្នំពេញ?

**ឆ៖** ដែលជម្លៀសហ្នឹង ជម្លៀសទាំងកងទ័ព ទាំងប្រជាជនមកបាទ។ វាចូលច្របូកច្របល់ជាមួយគ្នាដែលគេត្រូវជម្លៀសមកហ្នឹង។ ទាំងប្រជាជន ទាំងកងទ័ព ហើយនិងទ័ពដាក់មួយឡែក។ ដាក់ហ្នឹងដាក់គឺថា នេះទ័ព ហ្នឹងហើយកងទ័ព លន់ នល់។ រួចប្រជាជនហ្នឹងមកតាំងពីចេញពីទីក្រុងមក ខ្លះរែកកូន ខ្លះអូសរទេះ ខ្លះម៉ូតូអ៊ីចឹងមកហ្នឹង។

**ស៖** សូមទោសលោកសាក្សី។ សាក្សីខ្ញុំត្រូវតែកាត់លោក ខ្ញុំសូមទោសដែលខ្ញុំកាត់លោក។ ប៉ុន្តែខ្ញុំចង់ដឹងថា កាលពីម្សិលមិញលោកនិយាយថាទាហានហ្នឹងមកពីភ្នំពេញ តើលោកអាចប្រាប់បានដែរឬទេថាលោកដឹងមកពីណាដែរ? គឺថាលោកដឹងទាហានហ្នឹងមកពីភ្នំពេញហ្នឹង តើលោកដឹងដោយរបៀបណា ហើយអ្នកណាជាអ្នកប្រាប់លោកដែរអំពីបញ្ហានេះ សូមលោកប្រាប់ខ្ញុំ?

[០៩:៥៧:៣៤]

**ឆ៖** ប្រជាជនដែលប្រាប់ខ្ញុំហ្នឹង គឺគាត់មកជាមួយទាហាន។ ចង់បញ្ជាក់ថាអ៊ីចឹង។ ថាទាហានហើយនិងប្រជាជនដែលគេបញ្ជូនមកតាំងពីថ្នល់ទទឹងមក មកចូលមកដល់កន្លែងហ្នឹង។ ប្រជាជនថា

ទាហាន១ លន់ នល់ ហើយទាហាន លន់ នល់ ហ្នឹងមកសម្រាក គេឲ្យនៅខាងត្បូងវត្តព្រៃជុំហ្នឹងក្នុងត្រពាំងមួយធំ ហើយត្រពាំងហ្នឹងមិនធំប៉ុន្មានទេ គ្រាន់តែគេដាំបាយដាំទឹកអី គេជួយឧបត្ថម្ភ។ ព្រឹកឡើងគេយកទៅលិចទៅ គេថាទៅលើ ទៅរៀនសូត្រ បំពេញ បំពាក់ស័ក្តិឲ្យ អ្នកណាស័ក្តិប្រាំឲ្យស័ក្តិប្រាំ, អ្នកណាស័ក្តិមួយឲ្យស័ក្តិមួយ។ អាហ្នឹងតាមពាក្យដែលប្រជាជនដែលគាត់ទៅជួយឧបត្ថម្ភរឿងបាយទឹកឲ្យគាត់ហ្នឹង។ ហ្នឹងប្រាប់ខ្ញុំថាអ៊ីចឹង។ ហើយវាជិតដែរ ព្រៃជុំ ហើយនិងត្រពាំងហ្នឹង។ បានជាខ្ញុំដឹងថាដឹងគេជម្លៀសតាំងពីតាមថ្នល់ជាតិលេខ៤ មក១បែកគ្នានឹងផ្សារ--

[០៩:៥៩:០៣]

**ស៖** លោកសាក្សី តើលោកដឹងដោយ -- បានន័យថាតើលោកមានដឹងថាទាហាន លន់ នល់ ហ្នឹង -- ខ្ញុំចង់សួរអ៊ីចេះ តើលោកស្គាល់ទាហាន លន់ នល់ ហ្នឹងណាម្នាក់ដែរទេក្នុងចំណោមជាង ១០០ នាក់នុ៎ង?

**ឆ៖** ខ្ញុំអត់បានដឹងទេ អត់បានដឹងស្គាល់ទាហានណាម្នាក់អត់មានទេ។ ដឹងតែទាហាន។ ខ្ញុំអត់បានទៅជិតដល់សួរនាំថា ឥឡូវទាហានហ្នឹងនៅឯណា អីឯណា កងទ័ពហ្នឹងវានៅខាងណា ដែលគេជម្លៀសមកហ្នឹង ខ្ញុំអត់បានរាក់ទាក់សួរនាំអីទេ។ ប៉ុន្តែគ្រាន់តែគេថា ដែលជម្លៀសមកហ្នឹងដើរតាមផ្លូវមក វាមកដល់ថ្នល់ទទឹងហ្នឹងគេឲ្យដើរកាត់មកសំដៅធ្លាក់មកភូមិជើងរាស់ហ្នឹង។ អាហ្នឹងដែលខ្ញុំបានដឹង។ ដែលប្រជាជន ដែលគាត់មកសម្រាកនៅហ្នឹងព្រៃជុំហ្នឹងរាប់ពាន់ ហ្នឹងហើយ គ្រាន់តែប្រជាជនជម្លៀសមកហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ប៉ុន្តែខ្ញុំចង់សួរអ៊ីចេះ តើលោកស្គាល់ពួកគាត់ហ្នឹងដោយផ្ទាល់ឬក៏យ៉ាងណា ហើយលោកឆ្លើយថាអត់ទេ។ ឥឡូវនេះ ខ្ញុំចង់សួរបន្តទៀត។ កាលពីម្សិលមិញលោកបាននិយាយថា ហើយខ្ញុំសូមដកស្រង់ពាក្យរបស់លោក ពួកគេមិនដែលត្រឡប់មកវិញទេ។ ឥឡូវនេះ ខ្ញុំចង់សួរអ៊ីចេះ ប្រសិនបើលោកមិនស្គាល់ទាហានណាម្នាក់នោះទេ តើលោកធ្វើម៉េចដឹងថាពួកទាហានហ្នឹងគាត់អត់មានអ្នកណាម្នាក់ត្រឡប់មកវិញទេ តើលោកធ្វើម៉េចដឹងថាគេអត់ត្រឡប់មកវិញ បើលោកអត់ដែលស្គាល់ពួកគេផងនោះ?

[១០:០១:១២]

**ឆ៖** ដែលគេអត់ត្រឡប់មកវិញ ហេតុអ្វីដែលខ្ញុំមិនដឹង? ដែលដឹងហ្នឹង គឺអត់ដែលឃើញត្រឡប់មកវិញ បានជាខ្ញុំថាអត់ដឹង ប៉ុណ្ណឹង។ ដឹងគេយកទៅបង្រៀនសូត្រនៅឯណា។ រួចដឹងត្រឹមប៉ុណ្ណឹង។

ដឹងថាគេបញ្ជូនមកឲ្យរៀន រួចក្រោយមកទៀតវាអត់ឃើញមក។ ឲ្យដឹងថា អ្នេ--

**ស៖** ប៉ុន្តែលោកសាក្សី ប្រហែលជាខ្ញុំស្តាប់លោកច្បាស់ ឬក៏អត់យល់។ ប្រសិនបើខ្ញុំចង់និយាយអ៊ីចេះ ប្រសិនបើលោកអត់ស្គាល់ទាហានហ្នឹងទេ អត់ដឹងថាទាហានហ្នឹងនៅទីណា ទាហានហ្នឹងមកពីណាទេ។ ឥឡូវខ្ញុំចង់ដឹងថា ធ្វើម៉េចបានលោកអាចនិយាយបានថាទាហានហ្នឹងអត់ត្រឡប់មកវិញទេ? អាចថាមានទាហាន លន់ នល់ ណាម្នាក់គាត់ត្រឡប់មកវិញ ឬក៏អត់អី។ តើលោកយល់យ៉ាងម៉េចហ្នឹង? ខ្ញុំចង់សួរអ៊ីចឹង តើលោកធ្វើយ៉ាងម៉េចបានដឹងថាធ្វើ -- អត់មានអ្នកណាត្រឡប់មកវិញអ៊ីចឹង?

[១០:០២:២៣]

**ឆ៖** ចុះបើខ្ញុំនៅ នៅធ្វើឃុំជើងរាស់ហ្នឹង។ វាអត់ឃើញត្រឡប់មកមែន មិនដឹងជាទៅឯណា វាទៅលិចបាត់អស់រលីងហើយ។ ឲ្យខ្ញុំដឹងអាម៉េចទៀត។ ខ្ញុំដឹងត្រឹម ខ្ញុំអាដែងខ្ញុំឃើញ ហើយត្រឡប់មកវិញ គឺខ្ញុំអត់បានឃើញ បានខ្ញុំអត់ដឹង។

**ស៖** លោកសាក្សី ខ្ញុំចង់ដឹងថាតើលោកស្មាន ឬក៏លោកទាយទេថាអត់មាន ពួកទាហានហ្នឹងអត់ត្រឡប់មកវិញផ្ទះ។ តើជាការស្មានដែរឬទេ?

**ឆ៖** ថាស្មានក៏ថាបាន មិនស្មានក៏ថាបានដែរ ត្បិតអីវាអត់ឃើញមកវិញ។

**ស៖** ខ្ញុំមានសំណួរចុងក្រោយទៅលើប្រធានបទនេះលោកសាក្សី។ ម្សិលមិញលោកបាននិយាយថា លោកបានឮថា មនុស្សទាំងអស់ហ្នឹងត្រូវបានគេយកទៅរៀនសូត្រ។ ឥឡូវនេះខ្ញុំដកស្រង់សម្តីដែលលោកនិយាយ "ពួកគេត្រូវគេចាត់តាំងឲ្យទៅស្លាប់"។ តើលោកសាក្សី តើលោកខ្លួនលោកផ្ទាល់ហ្នឹងដឹងថាទាហាន លន់ នល់ ត្រូវបានគេសម្លាប់ ឬមួយយ៉ាងម៉េចដែរ?

[១០:០៤:០៤]

**ឆ៖** ត្រង់ហ្នឹង ខ្ញុំវាអត់បានទៅជាមួយទេ ដែលដឹងហ្នឹង។ គឺថាអ្នកដែលមានស័ក្តិទាំងប៉ុន្មានហ្នឹង គឺគេ អាដែងគេឲ្យស័ក្តិទៅការរៀនសូត្រ អ្នកណាតូច អ្នកណាធំ តាមកងហ្នឹងទៅ។ អាហ្នឹងដែលគេនិយាយមកហ្នឹង។ រួចដែលគាត់និយាយហ្នឹង និយាយនៅខាងជើងវត្តព្រៃជុំហ្នឹង។ ហ្នឹងនិយាយហ្នឹងដែលខ្ញុំបានដឹងកន្លែងហ្នឹង។ ត្រង់គេយកទៅសម្លាប់ ឬក៏គេយកទៅរៀនសូត្រ ក៏ខ្ញុំអត់បានដឹងដែរទេ។ ដែលពាក្យនិយាយគេថា ដែលដឹង ប្រជាជនដែលយកបាយទឹកទៅឲ្យកងទ័ពហ្នឹងគាត់អត់ដឹងខ្លួនថាយ៉ាងម៉េចដែរទេ។ ទាហានហ្នឹងនឹកថា អង្គការឲ្យទៅរៀនបំពេញវិជ្ជាធ្វើទ័ព។ ហ្នឹងដែលខ្ញុំដឹង គឺដឹងប៉ុណ្ណឹង។

**ស៖** លោកសាក្សីលោកនិយាយថា លោកបានឮពីអ្នកដទៃ ដែលថាទាហានហ្នឹងត្រូវបានគេ

បញ្ជូនទៅរៀនសូត្រ។ តើលោកអាចប្រាប់បានដែរឬទេ ថាពួកមនុស្សដែលប្រាប់លោកហ្នឹងគេដឹងអំពីរឿងហ្នឹងច្បាស់ គេអាចទុកចិត្តបាន ឬក៏យ៉ាងម៉េចដែរ? លោកអាចប្រាប់បានដែរទេ ថាអាចទុកចិត្តបានប្រភពអ្នកដែលប្រាប់លោកនោះជាអ្នកប្រាប់ដែលអាចទុកចិត្តបាន?

[១០:០៦:០៤]

**ឆ៖** អ្នកដែលប្រាប់បានហ្នឹង គឺមូលដ្ឋានដែលជួយយកស្បៀងអាហារទៅឲ្យគាត់ហ្នឹង គ្រប់ប្រជាជនដែលប្រជាជនចាស់ហ្នឹង។ ឲ្យទាំងពីប្រជាជនជម្លៀសទៅក៏គាំទ្របាយកញ្ចប់ ហើយម្ហូបម្ហាអីដែលប្រជាជននៅក្នុងភូមិព្រៃជុំហ្នឹង។ ហើយមួយចំណែកទៀត ប្រជាជនចាស់ហ្នឹងទៅជួយផ្តល់នូវស្បៀងអាហារឲ្យគាត់ហើយសុទ្ធទាហាន។ ហើយទាហានហ្នឹងវាថាឲ្យទៅរៀនសូត្រ។ ហើយខ្ញុំបានដឹងតែប៉ុណ្ណឹងទេ ខ្ញុំមិនមែនថា ហ្អេ! ដឹងហើយមិនជម្រាបជូននៅក្នុងអង្គប្រជុំនេះ។ បើដឹងគឺថាទៅរៀននៅកន្លែងណា ឧទាហរណ៍ថាទៅលើៗអីចឹង មិនដឹងជាទៅយ៉ាងម៉េច? មិនដឹងជាថា គេសម្លាប់ក៏ខ្ញុំមិនដឹងផុតពីកន្លែងខ្ញុំបាត់ហើយឲ្យខ្ញុំដឹងម៉េចបាន។ ហ្នឹងសូមជម្រាបជូនតែប៉ុណ្ណឹងទេ។

**ស៖** លោកសាក្សីលោកបាននិយាយថា ប្រជាជនយកម្ហូបអាហារ ស្បៀងអាហារទៅឲ្យទាហាន តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ? ដូច្នេះហើយលោកក៏រស់រានមានជីវិតផងដែរ។ ហេតុអ្វីបានជាលោកម្សិលមិញនិយាយថា ទាហានទាំងអស់នោះត្រូវបានគេយកទៅសម្លាប់ចោលប្រសិនបើពួកគេមានម្ហូបអាហារគ្រប់គ្រាន់ដែរនោះ?

[១០:០៨:០២]

**ឆ៖** ខ្ញុំគ្រាន់តែសន្និដ្ឋានថា បើទៅលើហ្នឹងសង្ស័យ -- អានេះពាក្យសម្តីខ្ញុំទេ គំនិតខ្ញុំទេ ខ្ញុំថាបើទៅលើប្រហែលជាគេ -- អានេះគ្រាន់តែប្រហែលទេអត់បានឃើញទេ គ្រាន់តែប្រហែលថា ប្រហែលជាគេសម្លាប់បានអត់ឃើញត្រឡប់មកវិញ។ ហ្នឹងគ្រាន់តែខ្ញុំថាប្រហែល បើអត់ឃើញមកវិញប្រហែលជាគេសម្លាប់ចោល។ ខ្ញុំគំនិតខ្ញុំដែលថា --

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកសាក្សីដែលលោកបានផ្តល់ពន្លឺភស្តុតាង ចម្លើយរបស់លោកបានឆ្លើយប្រាប់យើងខ្ញុំ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ

សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញលោកស្រីមេធាវី!

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោកនូ ម៉ៅ។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីការពារក្តីលោក ខៀវ សំផន។ ខ្ញុំសូមសួរសំណួរលោកមួយចំនួនពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកកាលពីម្សិលមិញនិងនៅថ្ងៃនេះ។ ប្រសិនបើសំណួរខ្ញុំមានភាពមិនច្បាស់លាស់នោះសូមលោកបង្អាក់ខ្ញុំហើយសុំឱ្យខ្ញុំបំភ្លឺសំណួរខ្ញុំឱ្យបានច្បាស់។ ជាបឋមខ្ញុំចង់ត្រឡប់មកនិយាយអំពីកិច្ចសម្ភាសន៍របស់លោកជាមួយលោក ប៉ែន ឃៀរនិន កាលពីប៉ុន្មានឆ្នាំមុន។ នៅពេលដែលនិយាយអំពីកិច្ចសម្ភាសន៍នេះ លោកឆ្លើយថា-- លោកបាននិយាយជាមួយនឹងអ្នកកាសែតអន្តរជាតិ។ ដូច្នេះ ខ្ញុំចង់សួរលោកថា លោក ប៉ែន ឃៀរនិន ហ្នឹងគាត់ណែនាំខ្លួនគាត់ប្រាប់លោកថាគាត់ជាអ្នកកាសែតអន្តរជាតិ អ៊ីចឹងទេ?

[១០:១០:៣១]

**ឆ៖** ខ្ញុំត្រង់ហ្នឹង ខ្ញុំគ្រាន់តែ កាសែតដែលគាត់មកយកព័ត៌មាននៅក្នុងសមរភូមិជួបខ្ញុំ។ ខាងយោធាហ្នឹង ខាង ប៉ុល ពត ហ្នឹង ជាខាងផ្នែកយោធាហ្នឹង។ រួចខ្ញុំគេប្រើឱ្យចូលយកស្បៀងអាហារប្រមូលប្រជាជន យុវជន ផ្តល់នូវស្បៀងអាហារ បាយកញ្ចប់ ឱ្យសែងរបួស។ ជួលខ្ញុំនៅក្នុងចំណោមហ្នឹង គាត់មកជួបខ្ញុំ ជួបខ្ញុំ មកយកសារព័ត៌មានហ្នឹងសួរ សួរថា "ខ្មែរក្រហមហ្នឹងវាបានទ័ពពីណាមក? ហើយស្បៀងអាហារហ្នឹង តើមានសេដ្ឋកិច្ចឧបត្ថម្ភទ័ពខ្មែរក្រហមហ្នឹង វានៅកន្លែងណា?" ខ្ញុំថា--

**ស៖** លោកសាក្សី ខ្ញុំចង់ឱ្យឆ្លើយឱ្យច្បាស់ ខ្ញុំដឹងហើយថាសំណួរអាចមិនច្បាស់ ក៏ប៉ុន្តែសូមឱ្យលោកឆ្លើយឱ្យច្បាស់ ហើយខ្លីៗបានហើយ កុំឆ្លើយវែងៗពេក។ ដូច្នេះ សូមឱ្យលោកមេត្តាធ្វើយ៉ាងណាឆ្លើយឱ្យត្រង់ទៅនឹងសំណួររបស់ខ្ញុំ។ លោកបានឆ្លើយយ៉ាងវែងអំមិញនេះ ហើយក្នុងនុ៎ងលោកលើកឡើងអំពីអ្នកកាសែតមួយរូបនៅសមរភូមិ។ តើអ្នកកាសែតដែលលោកនិយាយហ្នឹង ជាលោក ប៉ែន ឃៀរនិន ហ្នឹង ឬក៏មិនមែនទេ?

**ឆ៖** បើតាមដែលគាត់មកសម្ភាសខ្ញុំហ្នឹង ខ្ញុំ គាត់ហ្នឹងហើយដែលមកយកព័ត៌មានពីសមរភូមិទៅ។

[១០:១២:៥៥]

**ស៖** ដូច្នេះ ដើម្បីឆ្លើយតបនឹងសំណួររបស់ខ្ញុំមុននោះ លោកថា គាត់ជាអ្នកកាសែត គឺថាគាត់បង្ហាញខ្លួនក្នុងនាមជាអ្នកកាសែតនៅចំពោះមុខលោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែនបាទ គាត់ជាអ្នកកាសែត គាត់ថាអ៊ីចឹង "ខ្ញុំជាអ្នកកាសែតយកព័ត៌មានពីសមរភូមិ"។

**ស៖** នៅពេលដែលលោកនិយាយថានៅសមរភូមិ តើយើងអាចនិយាយបានថា លោកលើកឡើងអំពីសមរភូមិ ក៏ប៉ុន្តែគឺថាសមរភូមិក្រោយឆ្នាំ១៩៧៥ទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** កន្លងផុតយូរហើយ បើគិតពីឆ្នាំ ជាង៣០មកហើយ ខ្ញុំដូចថាការចងចាំហ្នឹងវាយូរពេកទៅហើយ។

**ស៖** ខ្ញុំដឹងហើយថា វាកើតឡើងមកយូរមកហើយ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងថា តើក្រោយ៧៥ទេមែនទេ គឺថាក្រោយពេលដែលវៀតណាមវ៉ៃចូលមកទីក្រុងភ្នំពេញរួចមកហើយទេ?

[១០:១៥:៤១]

**ឆ៖** នៅក្នុងសមរភូមិមានទាហាន លន់ នល់ ដែលម្ខាងខាងដីខ្មែរក្រហម, ម្ខាងខាងដីលន់ នល់ចាន់ -- កាលហ្នឹង ច័ន្ទ រង្សី គាត់អ្នកក្តាប់ខាងផ្នែកយោធាខាង លន់ នល់ មកវ៉ៃជាប់គ្នានៅស្រះឃ្លាំង។ អ៊ីចឹងគាត់មកយោធានាំមកឱ្យខ្ញុំ រួចខ្ញុំថា -- អានេះនិយាយវែងបន្តិចចុះ -- ខ្ញុំថា អឺ! ខុសពីខ្ញុំហ្នឹងខ្មែរក្រហមអត់ទុកទេ។ ឥឡូវសម្លាសខ្ញុំរួចទៅ ខ្ញុំថាឥឡូវរត់ចេញពីកន្លែងហ្នឹងចូលដីទ្រង់ ច័ន្ទ រង្សី ទៅ។ រួចគាត់ថា អត់អីទេ ទោះបីយ៉ាងម៉េច ក៏ខ្ញុំនៅសន្ទួចយកព័ត៌មានទាល់បាន។ អ៊ីចឹងគាត់សម្ភាស ខ្ញុំសួរថា -- នេះនិយាយដូចច្រំដែល -- គាត់ថាខ្មែរក្រហមបានស្រូវបានអង្ករមកពីណា? ខ្ញុំថាខ្មែរក្រហមសមរភូមិក្រោយឧបត្ថម្ភសមរភូមិមុខ។ អ៊ីចឹង ខ្ញុំក៏ថា ខ្លាចគេតាមដាន--

**ស៖** លោកសាក្សីសូមអភ័យទោសដែលខ្ញុំកាត់ផ្តាច់លោក។ ខ្ញុំចង់ឱ្យលោកឆ្លើយបញ្ជាក់ នៅពេលដែលខ្ញុំសួរលោកថានៅសមរភូមិណា ដែលលោកលើកឡើងឆ្លើយទៅនឹងអ្នកកាសែតនោះ? លោកឆ្លើយថាជាសមរភូមិប្រយុទ្ធវ៉ៃ លន់ នល់ – វ៉ៃទាហាន លន់ នល់។ ដូច្នេះលោកបញ្ជាក់ថា ការសម្ភាសលោកជាមួយនឹង ប៉ែន យៀរនិន ហ្នឹងគឺកើតឡើងមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ មែនទេ? មានន័យថាការសម្ភាសលោកហ្នឹងគឺប្រព្រឹត្តទៅមុនពេលដែលទាហានខ្មែរក្រហមវ៉ៃឈ្នះទាហាន លន់ នល់ អ៊ីចឹងមែនទេ?

[១០:១៧:៣៣]

**ឆ៖** បាទ ត្រង់ហ្នឹងមិនទាន់ឈ្នះមិនទាន់ចាញ់ទេកន្លែងហ្នឹង ដែលនៅវ៉ៃហ្នឹង ដែលគាត់មកសម្លាសហ្នឹង នៅជាប់គ្នា។ ទាហាន លន់ នល់ ឈរជើងនៅស្រះឃ្លាំង ហើយខ្មែរខាងខ្មែរក្រហមវានៅជាប់តែគ្នាហ្នឹង នៅសមរភូមិខណ្ឌគ្នា។ អ៊ីចឹងត្រៀមទាំងអស់គ្នា ខាងណោះក៏មិនឲ្យទាហាន លន់ នល់ចូល ពីនេះទៅក៏អត់ឲ្យខ្មែរក្រហមចូល។ អ៊ីចឹងដល់ពេលផ្ទុះអាវុធត្រូវវ៉ៃគ្នា ហើយពេលនោះគ្រាន់តែកប៉ាល់ហោះ -- អានេះនិយាយវែងបន្តិចចុះ -- ទម្លាក់គ្រាប់បែក ហើយអ្នកដែលទៅហ្នឹងប្រជាជនដែលយកបាយកញ្ចប់ទៅផ្តល់ឲ្យទ័ព រួចខ្ញុំហ្នឹងក៏គេប្រើឲ្យទៅជួយយុវជននារី សែងខ្មោច ដែលខ្មោចដែលត្រូវគ្រាប់ផ្លោង--

[១០:១៨:៤៩]

**ប្រធានអង្គជំនុំ៖**

លោក ម៉ៅ ស្តាប់សំណួរឲ្យបាន ហើយលោកព្យាយាមយល់សំណួរ ហើយឆ្លើយតបទៅនឹងភាពចាំបាច់នៃសំណួរដែលសួរបានហើយ។ ម្យ៉ាងគឺវាជាការមិនសមស្របទេ នៅក្នុងការឆ្លើយ សួរ-ឆ្លើយនៅក្នុងនីតិវិធីចំពោះមុខតុលាការ។ ទី២ អង្គជំនុំជម្រះកត់សម្គាល់ឃើញមានបញ្ហាសុខភាព ដើម្បីបង្កើនល្បឿននៅក្នុងកិច្ចពិភាក្សាដេញដោលក្នុងនាមលោកជាសាក្សីចំពោះមុខអង្គជំនុំជម្រះហ្នឹងបានឆាប់ចប់។ អ៊ីចឹងសូមលោកស្តាប់ឲ្យយល់ ហើយនិងឆ្លើយតបឲ្យចំទៅនឹងសំណួរ។ ស្តាប់ឲ្យបាន ហើយខ្លីទេមិនវែងទេ។ សួរថាកិច្ចសម្ភាសន៍ដែលលោកធ្វើជាមួយនឹងលោក ប៉ែន យៀរនិន ហ្នឹងនៅមុនពេលថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ឬក៏ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ១៩៧៩?

**លោក នូ ម៉ៅ៖**

**ឆ៖** ត្រង់ហ្នឹងខ្ញុំបាទ អារឿងឆ្នាំវាយូរដែរមកហើយៗ បើអាចកំណត់ខែឆ្នាំហ្នឹងទាល់តែទៅមើលក្នុងឯកសារដែរបានដឹងថាឆ្នាំ៧៩ ឬក៏ចិតប៉ុន្មាន ខ្ញុំវាភ្លេចយូរយារដែរមកហើយ សូមអធ្យាស្រ័យ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី បើលោកមិនចាំអំពីថ្ងៃខែឆ្នាំនោះទេ ប៉ុន្តែលោកបានឆ្លើយថាជាការប្រយុទ្ធគ្នាជាមួយនឹងទាហាន លន់ នល់។ អ៊ីចឹងលោកអាចនៅតែរក្សាចម្លើយហ្នឹងទេថាសមរភូមិហ្នឹងគឺជាការប្រយុទ្ធគ្នាជាមួយទាហាន លន់ នល់?

**លោក ឃីត រេយ៉ន័រ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:២១:៣៤]

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន សំណួរនេះគួរតែសួរសំណួរ សួរដោយស្មោះត្រង់ទៅតាមចម្លើយរបស់សាក្សីកាលពីម្សិលមិញ ជាពិសេសអំពីកិច្ចសម្ភាសន៍ជាមួយនឹង ប៉ែន យៀរនិន។ ពាក់ព័ន្ធទៅនឹងខ្សែអាត់ថតសំឡេងជាមួយនឹង ប៉ែន យៀរនិន គឺថាខ្ញុំសូមលើកឡើងជូនសាក្សីថា កិច្ចសម្ភាសន៍ នៅក្នុងកិច្ចសម្ភាសន៍ពេលវេលាក្នុងកិច្ចសម្ភាសន៍ និងកាលៈទេសៈនៅក្នុងកិច្ចសម្ភាសន៍នោះ ប្រសិនបើតាមការគាត់ចាំ។ កិច្ចសម្ភាសន៍ធ្វើឡើងថ្ងៃទី២៦ ខែសីហា ឆ្នាំ៨១ ប្រសិនជាសាក្សីគាត់ចាំនោះ។ ខ្ញុំជំទាស់ទៅនឹងសំណួរដែលបានសួរអម្បាញ់មិញនេះ គឺដោយសារតែវាពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សី ឆ្លើយកាលពីម្សិលមិញធ្វើឡើងថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨១ ជាមួយនឹងលោក ប៉ែន យៀរនិន។

[១០:២២:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំយល់ពីកង្វល់របស់ព្រះរាជអាជ្ញា ក៏ប៉ុន្តែខ្ញុំគិតថាប្រហែលជាអាចមានបញ្ហាបកប្រែ ឬក៏ប្រហែលជាមានការបំប្លែងសម្ដីរបស់ខ្ញុំ។ នៅថ្ងៃនេះ ខ្ញុំមិនបានយោងទៅលើចម្លើយរបស់សាក្សីកាលពីម្សិលមិញទេ ខ្ញុំគ្រាន់តែចង់ឲ្យសាក្សីគាត់បញ្ជាក់ឲ្យច្បាស់ កាលពីគាត់ឆ្លើយកាលពីប៉ុន្មាននាទីមុននេះ។ ពីព្រោះថាប៉ុន្មាននាទីមុននេះគាត់និយាយថា មានការប្រយុទ្ធគ្នា។ ដូច្នេះខ្ញុំសួរថាតើមានការប្រយុទ្ធហ្នឹងរវាងអ្នកណានិងអ្នកណា? ពេលនោះគាត់និយាយថាជាការវ៉ៃទាហាន លន់ នល់។ ដូច្នេះសំណួររបស់ខ្ញុំអត់ពាក់ព័ន្ធនឹងចម្លើយរបស់គាត់កាលពីម្សិលមិញទេ គឺពាក់ព័ន្ធនឹងចម្លើយនៅថ្ងៃនេះ នេះជាចំណុចទី១។ ចំណុចទី២ ខ្ញុំនឹងត្រឡប់មកនិយាយអំពីកំណត់ត្រារបស់លោក ប៉ែន យៀរនិន ក៏ប៉ុន្តែកាលពីម្សិលមិញនោះខ្ញុំបានជំទាស់ទៅនឹងលក្ខខណ្ឌនៃការសួររបស់សហព្រះរាជអាជ្ញា ពីព្រោះថាខ្ញុំចង់ឲ្យគាត់សួរសំណួរបើកចំហដើម្បីឲ្យសាក្សីឆ្លើយសិន បន្ទាប់មកបាននិយាយអំពីកំណត់ត្រារបស់លោក ប៉ែន យៀរនិន។ ដូច្នេះខ្ញុំគិតថាការជំទាស់របស់សហព្រះរាជអាជ្ញានោះ គឺគ្មានមូលដ្ឋានទេ។ យើងទាំងអស់គ្នានៅព្រឹកនេះ យើងស្ដាប់ឮច្បាស់ណាស់ថា សាក្សីបានលើកឡើងអំពីទាហាន លន់ នល់។ ខ្ញុំមិនបានប្រឌិត ខ្ញុំមិនបានច្នៃ បង្កើតអីទេ។ គឺថានេះជាចម្លើយរបស់គាត់ ហើយខ្ញុំសួរបញ្ជាក់ទៅលើចម្លើយរបស់

គាត់។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីឲ្យខ្ញុំបន្តសួរសំណួរតទៅទៀត។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត។ សេចក្ដីជំទាស់មិនមានប្រសិទ្ធភាព មិនមានមូលដ្ឋានទេ។ អញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១០:២៤:៣៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីប៉ុន្មាននាទីមុននេះលោកបានលើកឡើងអំពីការជួបគ្នាជាមួយនឹងអ្នកកាសែតមួយរូបនៅលើសមរភូមិ។ នៅពេលដែលខ្ញុំសួរថា "នៅលើសមរភូមិនោះជាអ្នកកាសែត ប៉ែន យៀរនិន មែនទេ?" លោកឆ្លើយថា "បាទ គឺ ប៉ែន យៀរនិន ហើយ"។ ដូច្នេះខ្ញុំចង់សួរលោកឲ្យបានច្បាស់ម្ដងទៀតដើម្បីឲ្យលោកចងចាំ ថាតើអ្នកកាសែតដែលលោកជួបនៅលើសមរភូមិនោះ គឺពិតជា ប៉ែន យៀរនិន មែនទេ? ហើយដែលលោកមានរូបថតគាត់ ហើយលោកបានបង្ហាញកាលពីម្សិលមិញនោះ។ អ៊ីចឹងខ្ញុំសួរលោកម្ដងទៀតថា ពិតជា ប៉ែន យៀរនិន មែនទេដែលលោកជួបនៅសមរភូមិនោះ?

**ឆ៖** ខ្ញុំបានជួបផ្ទាល់ពិតមែន។

**កញ្ញា អង់តា ហ្គីសសេ៖**

ដើម្បីឲ្យយើងច្បាស់ទាំងអស់គ្នានោះ ខ្ញុំសូមឲ្យមន្ត្រីតុលាការបង្ហាញឯកសារដែលមានរូបថតលោក ប៉ែន យៀរនិន ដើម្បីឲ្យយើងប្រាកដទាំងអស់គ្នាថា យើងនិយាយពីបុគ្គលម្នាក់ហ្នឹងមែន។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញរូបថត។ ហើយមុនពេលប្រគល់រូបថតជូនសាក្សីនោះ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីឲ្យពិនិត្យមើលឲ្យច្បាស់ ពីព្រោះថាយើងមើលពីចម្ងាយទៅ យើងឃើញដូចជាមានអក្សរមួយនៅក្នុងរូបថតហ្នឹង។ អ៊ីចឹងយើងអត់អាចមើលឃើញអក្សរហ្នឹងបានទេ។ ដូច្នេះជាបឋមហ្នឹងសូមបង្ហាញរូបថតឲ្យយើងខ្ញុំផង ដើម្បីឲ្យយើងខ្ញុំអាចឃើញអក្សរដែលសរសេរនៅលើរូបថតនោះ ហើយបន្ទាប់មកនឹងបង្ហាញរូបថតនោះទៅកាន់សាក្សី ដើម្បីឲ្យសាក្សីគាត់បញ្ជាក់ឲ្យបានច្បាស់ថាតើយើងនិយាយពីបុគ្គលហ្នឹង ឬក៏មិនមែនទេ?

[១០:២៦:៣៤]

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី រូបថតកាលពីម្សិលមិញនៅឯណា? យកទៅជូនលោកស្រីមេធាវី!

បាទ ឥឡូវនេះដោយសារមានការប្រគល់នូវរូបថតនោះទៅខាង ស៊ី.អឹម.អេស ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ហើយពេលនេះមិនអាចយកភ្លាម បញ្ជូន ដើម្បីសួរដេញដោលនៅពេលនេះបានទេ ព្រោះត្រូវការពេលវេលាដើម្បីទាក់ទងជាមួយនឹងខាងគ្រប់គ្រងសំណុំរឿងដើម្បីទទួលបាននូវរូបថតនោះ ហើយពេលវេលាក៏សមស្របនឹងសម្រាកនឹងហើយដែរ។ សាក្សីក៏នឿយហត់ដែរ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

[១០:២៧:៣៥]

ហើយក្រឡាបញ្ជីទាក់ទងជាមួយនឹងខាងអង្គភាពគ្រប់គ្រងសំណុំរឿងដើម្បីទទួលយកបានមកវិញនូវរូបថតដែលអង្គជំនុំជម្រះបានទទួលយកពីសាក្សីដែលបានបង្ហាញកាលពីម្សិលមិញ យកមកដាក់ជូនទៅមេធាវីការពារក្ដីពិនិត្យ ហើយនិងដាក់ជូនសាក្សីពិនិត្យក្នុងការដេញដោលបញ្ជាក់បន្ថែមនៅក្រោយពេលដែលចូលមកវិញនេះ ក្រោយសម្រាក។

មន្ត្រីរដ្ឋបាលតុលាការផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៨ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយអង្គជំនុំជម្រះសូមរំឭកជូនដល់លោក ម៉ៅ ថា ទី១លោកស្ដាប់សំណួរឲ្យបានហើយឆ្លើយខ្លីៗតបទៅនឹងសំណួរចាំបាច់គ្រប់គ្រាន់

តបទៅនឹងសំណួរបានហើយ ជៀសវាងលោកអត្ថាធិប្បាយចេញឆ្ងាយពីសំណួរដែលសួរ។ ភាពចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរ ទី១។ ទី២ បើលោកមានការអស់កម្លាំងមិនអាចផ្តល់សក្ខីកម្មបានទេ គឺសូមផ្តល់ព័ត៌មានមកដល់យើង ដើម្បីយើងពិនិត្យពិចារណាសម្រេចលើបញ្ហានេះដូចកាលពីម្សិលមិញអ៊ីចឹងណ៎ា ព្រោះមើលទៅលោកមានបញ្ហាសុខភាពដោយសារវ័យចំណាស់របស់លោក។ ហើយសូមមេធាវីប្រឹក្សាសាក្សីជួយពិនិត្យលើបញ្ហានេះផង ដើម្បីអាចផ្តល់នូវការកត់សម្គាល់មកយើងដើម្បីយើងពិចារណាក្នុងលទ្ធភាពនៃការផ្អាកសវនាការក្នុងករណីស្ថានភាពសុខភាពរបស់គាត់មានលក្ខណៈអាចប្រឈមនឹងបញ្ហា។

ហើយសូមមេធាវីសម្រួលនូវសំណួរឲ្យបានងាយយល់ផង ហើយខ្លីៗដើម្បីឲ្យអាចសាក្សីងាយយល់ និងស្តាប់ ងាយឆ្លើយ។ បាទ អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១០:៥៤:៤៧]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងធ្វើការតាមណែនាំរបស់តុលាការ។

ពេលសម្រាកអម្បាញ់មិញនេះមន្ត្រីតុលាការបានផ្តល់រូបថត ដែលលោកសាក្សីបានផ្តល់ជូនកាលពីម្សិលមិញនេះ។ អ៊ីចឹងឥឡូវខ្ញុំសូមត្រឡប់រូបថតនេះ ទៅបង្ហាញគាត់វិញ ដើម្បីជាមូលដ្ឋាននៃការចោទសំណួររបស់ខ្ញុំ។ សូមអញ្ជើញមន្ត្រីតុលាការយករូបថតនេះទៅឲ្យគាត់។ ឥឡូវនេះ មានលេខកូដហើយរូបថតនេះ គឺ E1/209.2។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក នូ ម៉ៅ តើលោកស្គាល់រូបថតនេះទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំបាទស្គាល់ គាត់បានសម្ភាសខ្ញុំនៅក្នុងសមរភូមិ។ ក្រោយមកទៀត គាត់នឹងសម្ភាសខ្ញុំនៅរដ្ឋកម្ពុជានៅស្រុកខដុង្គ។ ដូច្នេះ វាពាក់ព័ន្ធនៅក្នុងរូបថតនេះ សម្ភាសខ្ញុំពីរដង។ នៅក្នុងសមរភូមិម្តងក្រោយមកនៅក្នុងរដ្ឋកម្ពុជានេះម្តង។ អ៊ីចឹងនៅលើសំណួរដែលសួរ--

**ស៖** លោកសាក្សី ខ្ញុំសូមកាត់លោកបន្តិច យើងទៅមុខជាជំហានៗ។ ខ្ញុំចោទសំណួរជាក់លាក់ទៅកាន់លោក។ ខ្ញុំសូមឆ្លើយឲ្យបានច្បាស់លាស់ ហើយបន្ទាប់មក ខ្ញុំចោទសំណួរបន្ថែម។ ធ្វើដូចនេះ

យើងអាចទៅមុខលឿន ហើយជៀសវាងការលំបាកមួយចំនួនដែលលោកប្រធានបានលើកឡើងអម្បាញ់មិញ។ សំណួរទី១ ទាក់ទងទៅនឹងរូបថតនេះ តើលោកទទួលរូបថតនេះនៅកន្លែងណា? អ្នកណាអ្នកផ្តល់រូបថតនេះជូនទៅលោក?

[១០:៥៧:១៥]

**ឆ៖** អ្នកដែលផ្តល់រូបថតហ្នឹង ដែលខ្ញុំមកហ្នឹងគាត់យករូបថតនេះ ខ្ញុំឃើញរបស់គាត់ គាត់សួរថា "ស្គាល់ទេ រូបថតនេះ?" ខ្ញុំថា ខ្ញុំមើលយូរទៅ ខ្ញុំថា "អ្ហ៎! ប្រហែលគាត់ហើយ ប៉ែន យៀវនិនហ្នឹង" ត្បិតអីជួបខ្ញុំបានពីរដង តែគ្រាន់តែថា មុខមាត់គាត់ស្រដៀងដែលគាត់យកព័ត៌មាននៅសមរភូមិ។ ក្រោយមកទៀត គាត់បានមកសម្ភាសខ្ញុំនៅរដ្ឋកម្ពុជានៅឧដុង្គ។ អ៊ីចឹង ខ្ញុំកំណត់ក្នុងខ្លួនចិត្តរបស់ខ្ញុំ ខ្ញុំថាបើប៉ាន់ជាអាយុខ្ញុំហើយនិងគាត់ មិនស៊ីសងគ្នាប៉ុន្មានទេ បាទ។ អ៊ីចឹងបានន័យថា ខ្ញុំវាច្បាស់បាត់ទៅហើយ ពិនិត្យទៅឃើញថាច្បាស់មែន។

**សៈ** សំណួរបន្តទៀតទាក់ទងទៅនឹងរូបថតហ្នឹង។ នៅខាងក្រោយរូបថតហ្នឹង មានចំណារមួយដែលជាចំណារពណ៌ខ្មៅ។ តើលោកអាចបញ្ជាក់បានទេថាអ្នកណាជាអ្នកសរសេរចំណារហ្នឹង? ហើយចំណារនិយាយអំពីអ្វីដែរ? លោកអាចអានចំណារហ្នឹងបានទេ? ឥឡូវហ្នឹង ខ្ញុំសូមស្នើលោកអានជាដំបូងអានសិន។

**ឆ៖** សំណើអានដែលបានជួបគាត់? ត្រង់ណាទៅ? ជួយមើលឲ្យផង។

**សៈ** គឺផ្នែកសរសេរប៊ិកពណ៌ខ្មៅនៅខាងក្រោមរូបថតហ្នឹងសរសេរជាភាសាខ្មែរលោក។ ហើយសំណេរផ្សេងៗទៀតហ្នឹង ថាជាចំណាររបស់នេះទេ ក្រឡាបញ្ជីទេ។ អ៊ីចឹងខ្ញុំសួរហ្នឹង ដែលថាចំណារពណ៌ខ្មៅហ្នឹង អ្នកណាជាអ្នកធ្វើ អ្នកសរសេរចំណារហ្នឹង? ហើយនិយាយពីអីដែរ?

[១១:០០:០២]

**ឆ៖** ខ្ញុំអត់យល់ៗត្រង់ហ្នឹង។ សម្គាល់គាត់មើលទៅវាក្នុងចំណារខ្មៅហ្នឹង រូប ចំពោះរូបគាត់ហ្នឹង ខ្ញុំវាភ្លេចដែរទៅ។ ហើយចំណារហ្នឹងមិនដឹង ដែលគាត់ឲ្យមកហ្នឹងឃើញអ៊ីចឹងមក បានខ្ញុំច្បាស់ហ្នឹង គាត់ហ្នឹងជា ប៉ែន យៀវនិន ហ្នឹង ដែលគាត់--

**សៈ** ខ្ញុំសួរថា អ្នកណាអ្នកឲ្យរូបថតហ្នឹងទៅលោក ហើយគាត់ឈ្មោះអីដែរ?

**ឆ៖** ខ្ញុំអត់ស្គាល់ឈ្មោះផងដែលគាត់យកមកឲ្យ។ មកហ្នឹង គាត់មកផ្ទះខ្ញុំ សួរថា -- ឲ្យមើលអ៊ីចឹង។ ដល់ខ្ញុំមើលទៅ សួរថា"ស្គាល់ទេ?" ខ្ញុំថា "ស្រដៀង។ ដល់យូរទៅ អ្ហ៎! គាត់ហើយ ច្បាស់ហើយ

ដែលគាត់ឲ្យមកហ្នឹង" ហើយអ្នកឲ្យហ្នឹងខ្ញុំ ដែលឲ្យមកខ្ញុំអត់ស្គាល់ដែរ ទាល់តែគាត់មកបញ្ជាក់ខ្ញុំតែប៉ុណ្ណឹង ហើយគាត់ទៅបាត់ទៅ។ ខ្ញុំអត់ស្គាល់ ហើយក្តាប់អត់បានដែរត្រង់ហ្នឹង គ្រាន់តែគាត់យកមកបង្ហាញ ហើយឯកសារទាំងអស់ហ្នឹងគាត់យកមកឲ្យ ហើយគាត់លើករូបថតហ្នឹងមក ខ្ញុំទំនាក់ទំនងមើលទៅថាគាត់ហ្នឹងដែលធ្លាប់សម្លាសខ្ញុំពីរដង។ អ៊ីចឹងខ្ញុំវាភ្លេចអ្នកឲ្យហ្នឹងទៀត ឲ្យរូបថតហ្នឹងមកខ្ញុំហ្នឹង។

[១១:០២:២៦]

**ស៖** ដោយមិនចាំពីឈ្មោះអ្នកដែលផ្តល់រូបថតហ្នឹងទៅលោកនោះ។ តើលោកអាចជម្រាបតុលាការបានទេថាបុគ្គលរូបហ្នឹងមកជួបលោកនៅពេលណាដែរ?

**ឆ៖** ដែលមកហ្នឹងនៅពេលដែលខ្ញុំដេកនៅលើ -- ដែលខ្ញុំមកនៅដល់ដេកនៅអគារ -- ភ្លេចទៀតហើយអគារអីទេ--

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបន្តសំណួរតទៅទៀត ហើយអង្គជំនុំជម្រះសូមជម្រាបថា តាមព័ត៌មានដែលអង្គជំនុំជម្រះទទួលបាន គឺរូបថតនេះ គឺអង្គភាពគាំពារសាក្សី និងអ្នកជំនាញជាអ្នកផ្តល់ឲ្យគាត់។

បន្តសំណួរផ្សេងទៀត ចាំបាច់ផ្សេងទៀតចុះ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងទាល់តែសោះថា អង្គភាពគាំពារសាក្សីហ្នឹងធ្វើការបែបនេះ។ គឺថាដោយបង្ហាញរូបថតទៅសាក្សីជាដើមនេះ។ អ៊ីចឹងយើងនឹងធ្វើសំណើមួយដាក់ជូនតុលាការដើម្បីឲ្យដឹងថា តើការងារនេះធ្វើយ៉ាងម៉េចដែរ ហើយអ៊ីចឹងយើងឆ្ងល់ណាស់ពីរបៀបធ្វើការនេះ។ ព្រោះថានៅពេលដែលសាក្សីមួយមកផ្តល់សក្ខីកម្មនៅទីនេះ ជាគោលការណ៍គឺថា គាត់ត្រូវ--

[១១:០៤:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសង្ឃឹមថា នឹងបំភ្លឺនូវអ្វីដែលបានកើតឡើង យើងបានទទួលដំណឹងនេះថ្មីៗនេះឯងតាមរយៈអ៊ីម៉ែលមួយរបស់តុលាការយើងនេះ។ គឺថាក្នុងការការងារធ្វើអ្វីមួយនោះ

ទាក់ទងទៅនឹងការឲ្យដឹងថា សាក្សីនៅកន្លែងណានោះ យើងមានព័ត៌មានតិចណាស់ ហើយអង្គភាពគាំពារសាក្សីហើយនិងអ្នកជំនាញនេះបានបង្ហាញរូបថតនេះទៅសាក្សី ដើម្បីឲ្យប្រាកដប្រជាថា សាក្សីនេះពិតជាសាក្សីដែលតុលាការត្រូវការមែន។ ហ្នឹងហើយគឺថាធ្វើដើម្បីកំណត់អត្តសញ្ញាណសាក្សីនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម ខ្ញុំយល់ពីការពន្យល់របស់លោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ដើម្បីជម្រាបជូនទៅខាងមេធាវីការពារក្តី។ រូបថតនេះត្រូវបានប្រើប្រាស់ដោយវេស្ស៊ី ក្នុងពេលសាកសួរដើម្បីគេរៀបចំយកសាក្សីមកឲ្យបានត្រឹមត្រូវ។ ហេតុដូច្នេះហើយទើបគេប្រើប្រាស់រូបថតនេះបង្ហាញនាពេលនោះ។ នៅពេលនេះគឺថា គឺលោកស្រីអាចបន្តសាកសួរបញ្ហាហ្នឹងទៀត ប្រសិនបើសួរបញ្ហាផ្សេងនោះគឺនៅពេលក្រោយអាចសួរទៅបាន។

[១១:០៦:០៥]

**កញ្ញា អង់តា ហ្គីសសេ៖**

ពិតហើយ យើងនឹងធ្វើយ៉ាងដូច្នេះតាមសេចក្តីណែនាំរបស់តុលាការ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក នូ ម៉ៅ លោកបានឆ្លើយថា លោកបានជួបបុគ្គលដែលមាននៅក្នុងរូបថតនេះដែលលោកថាគាត់ជា ប៉ែន យៀវនិន នេះ។ លោកបានជួបគាត់ពីរដង លោកបាននិយាយយ៉ាងដូច្នេះ។ តើជាការត្រឹមត្រូវដែរឬទេ គឺថាលោកបានជួបគាត់លើកទី១នោះនៅក្នុងសមរភូមិ ហើយជួបលើកទី២ នៅឧដុង្គនៅក្នុងមន្ទីរស្រុក នៅសាលាស្រុក។ តើខ្ញុំយល់ហ្នឹងត្រឹមត្រូវដែរឬទេលោកសាក្សី?

**លោក នូ ម៉ៅ៖**

**ឆ៖** ត្រឹមត្រូវហ្នឹងហើយ ខ្ញុំទទួលថាត្រឹមត្រូវ។

**ស៖** ដើម្បីឲ្យច្បាស់ទាំងអស់គ្នា តើលោកនៅរក្សាចម្លើយរបស់លោកអម្បាញ់មិញនេះគឺលោកឆ្លើយថាលើកទី១ នៅសមរភូមិ គឺថានៅពេលដែលកងទ័ពខ្មែរក្រហមច្បាំងគ្នាជាមួយទាហានលន់នល់។ លោកអាចបញ្ជាក់ចម្លើយរបស់លោកបានទេ លោករក្សាចម្លើយហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនអាចឆ្លើយបានទេ គ្រាន់តែគាត់អ្នកយកព័ត៌មានហ្នឹង វានៅក្នុងសមរភូមិមែន ហើយក៏បែកគ្នាទៅទឹកដីខាង លន់ នល់ ទៅ។ គាត់សម្ភាសខ្ញុំបានតែតិចទេ។

**ស៖** ខ្ញុំព្យាយាមសួរលោកម្តងទៀត។ អម្បាញ់មិញនៅពេលដែលយើងនិយាយពីសមរភូមិ លោកបានឆ្លើយថាទាហានខ្មែរក្រហមច្បាំងគ្នាជាមួយទាហាន លន់ នល់។ តើលោកចាំទេថាលោកបាននិយាយអ៊ីចឹងអម្បាញ់មិញនេះ ហើយលោករក្សាចម្លើយនេះរបស់លោកទេ?

[១១:០៨:៣៥]

**ឆ៖** ខ្ញុំបានចាំតែ -- ប្រហែលជាសម្ភាសហ្នឹងបានរវាងមិនដល់កន្លះម៉ោងផងហ្នឹងនៅក្នុងពេលនោះ ហើយក៏បែកគ្នាទៅ។ ខ្ញុំថា "ទៅ! ទៅឯណោះ ទឹកដី លន់ នល់ ប្រយ័ត្នគ្រោះថ្នាក់" ហើយបែកទៅគេតាមដានខ្ញុំទៀតថា លែង--

**ស៖** លោកសាក្សីខ្ញុំសូមកាត់លោក។ សំណួរខ្ញុំអម្បាញ់មិញនោះមិនមែនចង់ដឹងថាអ្វីដែលកើតឡើងចំពោះអ្នកកាសែតនោះពេលក្រោយទេ។ សំណួរច្បាស់លាស់ណាស់ ខ្ញុំចង់ថាតើអម្បាញ់មិញនេះក្នុងសវនាការនេះលោកបានឆ្លើយថា ពេលដែលលោកបានជួបអ្នកកាសែតហ្នឹង គឺលោកជួបនៅសមរភូមិនៅពេលដែលទាហានខ្មែរក្រហមច្បាំងគ្នាជាមួយទាហាន លន់ នល់។ លោកចាំទេៗ ថាលោកបានឆ្លើយអម្បាញ់មិញនៅក្នុងសវនាការហ្នឹងអ៊ីចឹងទេ?

**ឆ៖** ក្នុងសវនាការហ្នឹងមែន។

**ស៖** តើជា -- តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ គឺថាលោករក្សាចម្លើយលោកហ្នឹងថា ពិតជាទាហានខ្មែរក្រហមនិងទាហានលន់ នល់ ច្បាំងគ្នាមែននៅលើសមរភូមិហ្នឹង?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលនិយាយពីកិច្ចសម្ភាសន៍ទី២របស់លោកនៅសាលាស្រុកឧដុង្គ។ ឥឡូវនេះខ្ញុំនិយាយតែពីកិច្ចសម្ភាសន៍លើកទី២របស់លោកនេះទេ។ តើលោកយល់ច្បាស់ទេ កាលណាលោកយល់ច្បាស់ហើយ ខ្ញុំអាចបន្តទៀតបាន។

[១១:១០:៤៨]

**ឆ៖** កាសែតគាត់មកសម្ភាសខ្ញុំនៅឧដុង្គហ្នឹង មកឡានពីរដែរ ដើរស៊ើបសួររកខ្ញុំ។ ជួបខ្ញុំនៅកន្លែងស្រុក។ រួចគាត់ស្រាវជ្រាវរកខ្ញុំ។ ដល់អ៊ីចឹងខ្ញុំនៅហ្នឹង ឃើញខ្ញុំជួបខ្ញុំហ្នឹង គាត់បានសម្ភាសជាមួយខ្ញុំហ្នឹង។

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញានូវសំណួរមួយ លោកបានឆ្លើយថា លោកនិយាយជាភាសាខ្មែរកាលណោះ ហើយលោកមានអ្នកបកប្រែម្នាក់។ អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទត្រឹមត្រូវមែន។

**ស៖** ហើយលោកក៏បានឆ្លើយផងដែរថា លោកប្រហែលជាមិនសូវច្បាស់ទេ ប៉ែន យៀរនិន នេះដែលជាអ្នកសម្ភាសលោកនោះ លោកមិនប្រាកដថាគាត់ហ្នឹងបានធ្វើកំណត់ត្រាអីនោះទេ។ អ៊ីចឹងសំណួរខ្ញុំចង់សួរលោកថា តើអ្នកបកប្រែនោះបានអានកំណត់ត្រាលោក ប៉ែន យៀរនិន នេះជូនឲ្យលោកស្ដាប់ទេ? ពេលណា ថាអាចពេលក្រោយ ឬក៏ក្នុងពេលហ្នឹងតែម្ដង?

**ឆ៖** គាត់ដែលមានសម្ភាសជាមួយខ្ញុំហ្នឹង គឺសម្ភាសនៅឧដុង្គហ្នឹង គាត់មានឡានពីរដែលចូលមកសម្ភាសហ្នឹង ហើយក៏គាត់ឃើញខ្ញុំថាខ្ញុំហ្នឹង--

[១១:១២:៤៤]

**ស៖** លោកសាក្សី ខ្ញុំសូមអភ័យទោស ខ្ញុំសូមកាត់លោក។ សំណួរខ្ញុំអម្បាញ់មិញនេះគឺច្បាស់លាស់។ ខ្ញុំមិនចង់ឲ្យលោកនិយាយឡើងវិញអំពីវត្តមានអ្នកដែលនៅទីនោះទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើអ្នកបកប្រែពេលណាមួយនោះ គាត់បានអានកំណត់ត្រារបស់លោក ប៉ែន យៀរនិន ជូនឲ្យលោកស្ដាប់។ អ៊ីចឹងខ្ញុំគ្រាន់តែចង់ដឹងប៉ុណ្ណឹងទេ ថាតើលោកចាំថាមានអ្នកបកប្រែហ្នឹងបានអានកំណត់ត្រារបស់លោក ប៉ែន យៀរនិន ឲ្យលោកស្ដាប់ទេ?

**ឆ៖** បាទ ហ្នឹងហើយគាត់អានឲ្យខ្ញុំស្ដាប់ គាត់អ្នកបកប្រែ។

**ស៖** តើកំណត់ត្រាទាំងអស់នោះសុទ្ធតែត្រូវបានអានដោយអ្នកបកប្រែជូនលោកស្ដាប់មែនទេ? ឬក៏ -- ឥឡូវខ្ញុំសួរម្ដងទៀត។ តើអ្នកបកប្រែមានកំណត់ត្រានៅក្នុងដៃគាត់ ហើយគាត់អានកំណត់ត្រាហ្នឹងត្រឹមត្រូវតាមអ្វីដែលសរសេរតែម្ដង។ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំវា ដូចមិនចាំដែរ ប៉ុនដូច ក្រែងលោមនុស្សជូនទៅ វាភ្លេចភ្លាំងដែរកន្លែងត្រង់ហ្នឹងដែលគាត់សម្ភាសខ្ញុំហ្នឹង។

[១១:១៤:៤៦]

**ស៖** ចំណុចចុងក្រោយលើកំណត់ត្រានេះ មុនពេលដែលលោកមកសវនាការនេះលោកធ្លាប់បានអានកំណត់ត្រាជាភាសាខ្មែរដែលគេបានសួរសំណួរទៅលោកពីរថ្ងៃកន្លងមកនេះដែរឬទេ? ថាមុននឹងមកសវនាការនេះលោកបានអានកំណត់ត្រាជាភាសាខ្មែរនេះ។ លោកសាក្សីតើលោកយល់សំណួរខ្ញុំដែរឬទេ?

**ឆ៖** ខ្ញុំយល់សំណួររបស់លោក។

**ស៖** ខ្ញុំដឹងថាលោកយល់សំណួរខ្ញុំហើយ។ តែឥឡូវខ្ញុំសូមសួរម្តងទៀត។ សំណួរខ្ញុំអម្បាញ់មិញនេះគឺថា ខ្ញុំចង់ដឹងថាតើមុនពេលមកសវនាការនេះលោកបានអានកំណត់ត្រាជាភាសាខ្មែរដែលគេសួរលោកពីរថ្ងៃចុងក្រោយនេះគឺគេសួរលោកទៅលើកំណត់ត្រាជាភាសាខ្មែរនេះឯង។ អ៊ីចឹងសួរថាលោកបានអានកំណត់ត្រាហ្នឹងទេ មុននឹងមកចូលសវនាការនេះ?

**ឆ៖** ខ្ញុំបានអានដែរអានសាចុះសាឡើងនៅក្នុងឯកសារហ្នឹង។ តែគ្រាន់ថាអានទៅដូចថាវាការចងចាំវានៅមានការភ្លេច ភ្លេចនោះវាភ្លេចច្រើនមែន។ វាអត់ចាំ។

[១១:១៦:៥៤]

**ស៖** បាទខ្ញុំសូមបំភ្លឺចុងក្រោយ តើគេឲ្យកំណត់ត្រាជាភាសាខ្មែរជូនលោកនេះនៅពេលណាដែរប្រសិនបើលោកចាំ។ បើលោកមិនចាំទេ អត់បញ្ហាអីទេ។

**ឆ៖** ខ្ញុំអត់ចាំដែរ។ ការចងចាំនោះវាបាត់បង់អស់រលីងហើយ។

**ស៖** តើគេឲ្យកំណត់ត្រាជាភាសាខ្មែរនេះទៅលោក មុនពេលលោកមកផ្តល់សក្ខីកម្មនៅតុលាការនេះ ឬក៏ពេលដែលលោកមកដល់ហើយបានគេឲ្យកំណត់ត្រាជាភាសាខ្មែរនេះទៅលោក?

**ឆ៖** ឲ្យមុន កាលខ្ញុំនៅផ្ទះនោះ។ គាត់យកឯកសារហ្នឹងយកឲ្យខ្ញុំ។ ខ្ញុំចេះតែអានមើលតាមឯកសារនោះទៅ ខ្ញុំថាដូចជាច្រើនពេកអានទៅវាទាក់ទងនៅក្នុងឯកសារហ្នឹងវាវែងពេក។ អ៊ីចឹងខ្ញុំដល់ច្រើនពេក ខ្ញុំរកចាប់ត្រង់ណាមិនជាប់ ណាវាភ្លេចភ្លាំងច្រើនពេកទៅ។

**ស៖** តើកំណត់ត្រាហ្នឹង គេពេលដែលគេឲ្យកំណត់ត្រាទៅលោកហ្នឹង ក្នុងពេលជាមួយគ្នានឹងគេឲ្យរូបថតទៅលោកដែរឬក៏យ៉ាងម៉េច?

[១១:១៨:៥០]

**ឆ៖** មិនទាន់គេឲ្យទេរូបថតហ្នឹង។ គេឲ្យទៅអត់ទាន់មានរូបថតឲ្យផង ទើបតែខ្ញុំមក គេកោះហៅឲ្យមកហ្នឹងបានគាត់ឲ្យរូបថតមកខ្ញុំ។

**ស៖** ហើយកំណត់ត្រាជាភាសាខ្មែរដែលលោកបានទទួលនោះ លោកនៅចាំទេថាអ្នកណាអ្នកប្រគល់កំណត់ត្រាជាភាសាខ្មែរនោះជូនទៅលោក?

**ឆ៖** ខ្ញុំអត់ចាំឈ្មោះទេកាលដែលគាត់ឲ្យមកនោះ។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេថាតើគេឲ្យលោក១សប្តាហ៍មុនហ្នឹង ឆ្នាំហ្នឹង ឬក៏មុន

យូរមកហើយ គេឲ្យតាំងពីយូរមកហើយ?

**ឆ៖** ដែលឲ្យហ្នឹង ដែលទៅកោះហៅខ្ញុំមកកន្លែងតុលាការ។

**ស៖** ចាស យើងនឹងធ្វើសំណើមួយជូនតុលាការនៅពេលក្រោយ ឥឡូវខ្ញុំសូមបន្តសំណួរខ្ញុំទៀត។ លោកសាក្សី នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោកមេធាវី លោក នួន ជា កាលពីម្សិលមិញ លោកបានឆ្លើយថាលោកមានតំណែងមួយនៅក្នុងភូមិ គណៈកម្មាធិការភូមិ ហើយនិងគណៈភូមិ ហើយនិងគណៈឃុំ។ តើក្រៅពីមុខងារពីរហ្នឹង លោកមានកាន់មុខងារអីផ្សេងទៀតទេ? ខ្ញុំសូមបញ្ជាក់គឺខ្ញុំនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ។

[១១:២១:២៧]

**ឆ៖** ខ្ញុំនៅមិនទាន់ចូលកន្លែងជាសមាជិកឃុំ គេឲ្យខ្ញុំកាន់នៅភូមិបី គឺភូមិស្រះធុល ត្រពាំងធំ ក្រាំងសុទិន។ នេះគឺឋានៈរបស់ខ្ញុំនៅក្នុងភូមិ។

**ស៖** លោកសាក្សី ខ្ញុំសូមឲ្យលោកផ្តង់អារម្មណ៍បន្តិច នៅពេលដែលខ្ញុំសួរសំណួរទៅលោក។ សំណួរខ្ញុំអម្បាញ់មិញនេះ ខ្ញុំចង់ដឹងថា ក្រៅពីគណៈឃុំ ហើយនិងគណៈភូមិ គណៈឃុំនេះ តើលោកមានកាន់មុខងារអ្វីផ្សេងទៀតទេ?

**ឆ៖** ដែលខ្ញុំគេដាក់ឲ្យកាន់បីភូមិហ្នឹង នៅក្នុងភូមិទេ មិនចូលនៅក្នុងជួរគណៈឃុំនៅឡើយទេ គេចាត់តាំង។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី ទំនងជាត្រូវការពេលវេលាប្រហែលជាប៉ុន្មានទៀតក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំត្រូវការប្រហែលជា៤៥នាទីទៀត លោកប្រធាន។

បើសិនជាការចោទសំណួរទៅថាដំណើរទៅមុខលឿននោះ ប្រហែលជាត្រូវការពេលតិចជាងហ្នឹង ប៉ុន្តែពេលខ្លះហ្នឹង ខ្ញុំសួរសំណួរច្រើនទម្រាំតែបានចម្លើយមួយ។ អ៊ីចឹងហើយខ្ញុំផ្តល់ពេលវេលាជូនលោកប្រធានថា ៤៥នាទីហ្នឹង ដោយយោងទៅលើស្ថានភាពលំបាកហ្នឹង។

[១១:២៣:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៤:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ គឺថាដោយពេលវេលាដែលមេធាវីត្រូវការសួរសាក្សីរូបនេះ ក៏មានរយៈពេលវែងដែរ ហើយស្ថានភាព សុខភាពរបស់សាក្សីមើលទៅ គឺមិនអាចផ្ដង់អារម្មណ៍ក្នុងការឆ្លើយតបទៅនឹងសំណួររបស់ -- ដែលសួរឡើងដោយមេធាវីបានទេ ដើម្បីឲ្យ ទុកលទ្ធភាពឲ្យមេធាវី -- សាក្សីរូបនេះឈប់សម្រាកបានច្រើនបន្តិចដើម្បីមានឱកាស ឬក៏មានកម្លាំងដើម្បីផ្ដង់អារម្មណ៍ ដើម្បីឆ្លើយតបទៅនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្ដីលោក ខៀវ សំផន។ អង្គជំនុំជម្រះសម្រេចសម្រាកនៅព្រឹកនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅរសៀលនេះ ចាប់ផ្ដើមពីម៉ោងមួយសាមសិបនាទី។

លោក ម៉ៅ ឥឡូវនេះអង្គជំនុំជម្រះសម្រេចសម្រាកហើយដោយសារបញ្ហាសុខភាពរបស់លោកមើលទៅមានបញ្ហាសុខភាព ហើយការផ្ដង់អារម្មណ៍ក្នុងការស្ដាប់នូវសំណួរ ដើម្បីឆ្លើយតបនឹងសំណួរក៏មានបញ្ហាដែរ។ អ៊ីចឹងអង្គជំនុំជម្រះមិនអាចបន្តធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោកឲ្យបានអស់លទ្ធភាពនៅព្រឹកនេះទេ ហើយសវនាការលើកបន្តទៅធ្វើនៅរសៀលទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកផ្ដល់សក្ខីកម្មនៅពេលរសៀលទៀត ហើយនៅរសៀលនេះទំនងចប់នៅវគ្គមួយនៃសវនាការនៅរសៀលនេះហើយ។

[១១:២៦:១២]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬ/និងជំនាញ ឬក៏កន្លែងណាមួយសមស្របដល់សាក្សីរូបនេះ សម្រាកនៅក្នុងអំឡុងពេលឈប់សម្រាកនេះ ហើយឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីផង មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយសាមសិបនាទី។

ហើយមន្ត្រីអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅរសៀលនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៦ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក នូ ម៉ៅ ខ្ញុំសង្ឃឹមថាលោកបានសម្រាកមានកម្លាំងហើយក្នុងពេលមុននេះបន្តិចនេះ។ ឥឡូវនេះខ្ញុំត្រឡប់មកសួរសំណួរដែលខ្ញុំបានសួរមុនពេលសម្រាក ដូច្នេះសូមឲ្យលោកយកចិត្តទុកដាក់ចំពោះសំណួររបស់ខ្ញុំ ខ្ញុំព្យាយាមសួរឲ្យបានច្បាស់បំផុតតាមដែលអាចធ្វើទៅបាន។ ខ្ញុំចង់ដឹងថាក្រៅពីលោកធ្វើជាគណៈភូមិ និងគណៈឃុំនោះ តើលោកមានតួនាទីផ្សេងទៀតទេក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

[១៣:៣៤:២៦]

**លោក នូ ម៉ៅ៖**

**ឆ៖** ក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹង ខ្ញុំមានឋានៈត្រឹមសមាជិកភូមិ ដែលគេឲ្យកាន់កាប់បីភូមិ ហើយនិងក្រោយមកទៀត សមាជិកឃុំ ចាត់តាំងឲ្យខ្ញុំ។

**ស៖** ហើយក្រៅពីជាសមាជិកភូមិ និងសមាជិកឃុំនេះ តើលោកមានមុខងារអីផ្សេងទៀតទេ?

**ឆ៖** ខ្ញុំអត់មានមុខងារការទេ មានតែសមាជិកឃុំហ្នឹង។ បម្រើការងារនៅក្នុងឃុំហ្នឹង។ ត្រូវគេចាត់តាំងឲ្យទៅណេះទៅណោះ។

**ស៖** កាលពីម្សិលមិញនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់មេធាវីការពារលោក នួន ជា គឺនៅក្រោយ -- ខ្ញុំសូមពិនិត្យមើលឯកសារយោងសិន គឺខ្ញុំពិនិត្យមើលប្រតិចារឹកសវនាការកាលពីម្សិលមិញ។ គឺក្រោយម៉ោង១០:២៨នាទីបន្តិច គឺនៅក្នុងសេចក្តីព្រាងប្រតិចារឹកកាលពីម្សិលមិញ។

**កញ្ញា អង់តា ហ្គីសសេ៖**

ដើម្បីកុំឲ្យមានបញ្ហាបកប្រែនោះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីចញ្ចាំងឯកសារនេះ ហើយលោកមេធាវី គង់ សំអុន គាត់នឹងអានជាភាសាខ្មែរក្រហមតែម្តង ដើម្បីកុំឲ្យមានបញ្ហា។

[១៣:៣៦:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអានជូននូវចំណុចដែលត្រូវដកស្រង់ ដែលជាសម្តីរបស់សាក្សី នូ ម៉ៅ។ "ឆ្លើយ៖ ចាន់ ស៊ីៗ គាត់ -- ខ្ញុំកាលនុំង ខ្ញុំក្តាប់អត់បានដែរ។ អាការចងចាំហ្នឹង វាបាត់បង់អស់ហើយ។ ចង់គាត់ដឹង ឬមិនដឹងយ៉ាងម៉េចដែរទេ។ ខ្ញុំវាត្រូវគ្រោះថ្នាក់ដែលនៅក្នុងសមរភូមិនោះ។ ខ្ញុំនៅតែព្យាបាលតាមពេទ្យនានាហ្នឹង ទិញថ្នាំពីតំបន់ភ្នំពេញមក។ ធ្វើអីកើត បើវាធ្លាក់ឈាម ទៅណាបាន បើនៅខ្លួនស្គមដូចកុកទៅហើយ។ ធ្វើអីទៀត តទៅទៀតអត់បានទេ"។ បាទ សូមបិទការដកស្រង់។ សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី កាលពីម្សិលមិញ លោកបានបញ្ជាក់ថា លោកមានរបួសនៅលើសមរភូមិប្រយុទ្ធ ហើយនៅពេលលោកឆ្លើយទៅនឹងសំណួររបស់មេធាវីការពារក្តី នួន ជា នោះ លោកបានប្រាប់ថាលោកមិនដែលមានមុខងារជាយោធាទេ។ តើលោកអាចពន្យល់បានទេថា មូលហេតុអ្វីបានជាលោកមានរបួសនៅក្នុង នៅលើសមរភូមិនោះ?

[១៣:៣៨:៤២]

**លោក នូ ម៉ៅ៖**

**ឆ៖** នៅក្នុងសមរភូមិ ក្រោយដែលខ្ញុំមិនទាន់មានរបួសនៅឡើយ --

**ស៖** ខាងខ្ញុំបានប្រាប់ថាប្រហែលជាមានបញ្ហាបកប្រែ។ អម្បាញ់មិញយើងអានឃ្លាដែលលោកបានឆ្លើយកាលពីម្សិលមិញ។ ក្នុងនោះ លោកថាលោកត្រូវគ្រោះថ្នាក់នៅសមរភូមិ គឺមានរបួស។ ដូច្នេះខ្ញុំចង់ដឹងថា ប្រសិនបើជាលោកមិនមានមុខងារយោធាទេ តើលោករបួសក្នុងកាលៈទេសៈបែបណាដែរ ក្នុងស្ថានភាពបែបណា?

**ឆ៖** ខ្ញុំមានរបួសហ្នឹង របួសក្រោយដែលពួកកាសែតហ្នឹងទៅសួរខ្ញុំ ខ្ញុំអត់ទាន់មានរបួសទេ។ ក្រោយមកបានខ្ញុំមានរបួសដោយសារតែធ្លាក់ពីលើអង្រឹងកប៉ាល់ហោះ ពេលវ៉ៃនៅភ្នំបាត ភូមិជើងរាស់ហ្នឹងបាទ។

**ស៖** លោកសាក្សីអម្បាញ់មិញនេះគឺយើងអានទូវចម្លើយរបស់លោកកាលពីម្សិលមិញ។ លោកអត់មាននិយាយអង្រឹង និយាយអីទេ។ លោកនិយាយអំពីគ្រោះថ្នាក់ ឬក៏របួសនៅសមរភូមិ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកពិតជាមានរបួសនៅសមរភូមិដែរឬទេ?

[១៣:៤១:១៤]

**ឆ៖** ត្រង់ហ្នឹងអត់មានទេ ដែលចូលទៅហ្នឹងអត់មានរបួសទេ ក្រោយមកកប៉ាល់ហោះដែលទម្លាក់នៅភូមិជើងរាស់ ភ្នំបាត។ហ្នឹង កប៉ាល់ហោះដែលវាមកទម្លាក់គ្រាប់បែកនៅភ្នំបាត ហើយខ្ញុំវាធ្លាក់ពីលើអង្រឹង វាត្រូវចុងស្មា ដល់យូរទៅ វាចេញធ្លាក់ឈាមអត់មានថ្នាំពេទ្យអីព្យាបាល ហើយក្អកមកសុទ្ធតែឈាមចេញឈាម។ សូមជូនបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមចូលទៅចំណុចផ្សេងទៀត។ លោកឆ្លើយថា បញ្ហាសុខភាពធ្វើឲ្យលោកត្រូវបានគេដកចេញពីមុខងារនៅថ្នាក់ឃុំ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ ដោយសារលោកមានបញ្ហាសុខភាពហ្នឹងហើយបានគេដកលោកចេញពីសមាជិកឃុំនោះ អ៊ីចឹងមែនទេ?

**ឆ៖** គេដកចេញពីសមាជិកឃុំដោយសារខ្ញុំមានរបួសធ្វើអីមិនកើត។

**ស៖** តើលោកចាំទេថា ប្រហែលជានៅពេលណាដែលលោកឈប់ធ្វើជាសមាជិកឃុំនោះ? តើមុនខ្មែរក្រហមទទួលបានជ័យជម្នះយូរហើយដែរឬទេ?

**ឆ៖** ពេលនោះ សម័យគេរៀបចំសហករណ៍ដែលបានជម្លៀសប្រជាជនមកពីទីក្រុងភ្នំពេញ។

**ស៖** អ៊ីចឹងលោកអត់ចាំទេថានៅឆ្នាំណានោះ។ អ៊ីចឹងមែនទេ?

**ឆ៖** អត់បានចាំទេ។

[១៣:៤៤:៣២]

**ស៖** ខ្ញុំចង់បង្ហាញជូនសាក្សីនៅឃ្លាមួយនៃកំណត់ត្រារបស់លោក ប៉ែន យៀវនិន។ ពាក់ព័ន្ធទៅនឹងចំណុចនេះ គឺឯកសារ D313/1.2.405, ERN ជាភាសាខ្មែរ 00909938, ERN ជាភាសាបារាំង 00893547, ERN ជាភាសាអង់គ្លេស 00419460។ ជាភាសាបារាំងគឺនៅឃ្លាចុងក្រោយ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញឃ្លានេះនៅក្នុងអេក្រង់។ នេះជាកំណត់ត្រាដែលគេបានកត់

ត្រានៅពេលសម្ភាស នេះបើតាម ប៉ែន យៀរនិន គាត់សរសេរថា "ខ្ញុំផ្លាក់ខ្លួនឈឺដោយបាត់បង់ឈាមចាប់តាំងពីឆ្នាំ១៩៧៤។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវគេជម្លៀសទៅកាន់ឃុំវល្លិ៍ស ក្នុងខេត្តកំពង់ស្ពឺក្រោយពេលរំដោះ"។ លោកសាក្សី ឥឡូវនេះតើលោកនឹកឃើញឡើងវិញហើយឬនៅ ថាលោកធ្លាក់ខ្លួនឈឺ បាត់បង់ឈាមហ្នឹងគឺនៅឆ្នាំ១៩៧៤?

**ឆ៖** ខ្ញុំធ្លាក់ខ្លួនឈឺហ្នឹងនៅក្នុងឆ្នាំដែលគេរៀបចំសហករណ៍ហើយ។ ការងារអីគេលែងទទួលស្គាល់ហើយ ជាសមាជិកសហករណ៍ឃុំដែរ តែគ្រាន់តែការងារគេលែងប្រើ ហើយគេដកសិទ្ធិរបស់ខ្ញុំទៀត។

[១៣:៤៦:៥៣]

**ស៖** លោកសាក្សី តើត្រឹមត្រូវដែរឬទេក្នុងការដែលនិយាយថា វគ្គរៀនសូត្រដែលលោកនិយាយនៅក្នុងសវនាការនេះគឺប្រព្រឹត្តទៅមុនពេលដែលលោកធ្លាក់ខ្លួនឈឺ គឺទាំងវគ្គរៀនសូត្រជាមួយ តាម៉ុក ឬក៏វគ្គរៀនសូត្រជាមួយនឹង ចាន់ ស៊ី?

**ឆ៖** កាលហ្នឹងដែលខ្ញុំមិនទាន់ធ្លាក់ខ្លួនមានជំងឺ ដែលជាសមាជិកឃុំ ដែល ចាន់ ស៊ី និង តាម៉ុក គ្រប់ឃុំ គ្រប់តំបន់ទាំងអស់ដែលខ្ញុំបានបញ្ជាក់ខាងដើមថា--

**ស៖** លោកសាក្សីសូមអភ័យទោសដែលខ្ញុំកាត់ចម្លើយលោក។ ជាថ្មីម្តងទៀត ខ្ញុំសោកស្តាយដែលត្រូវកាត់លោក។ ខ្ញុំចោទសួរសំណួរលោកហ្នឹងគឺច្បាស់លាស់ណាស់ ដូច្នេះខ្ញុំទៅមួយជំហានម្តងៗដើម្បីកុំឲ្យមានការភ័ន្តច្រឡំ។ លោកបាននិយាយថាមុន។ ឥឡូវនេះខ្ញុំនិយាយអំពីវគ្គរៀនសូត្រនេះ។ សំណួរទី១ពាក់ព័ន្ធទៅនឹងការប្រជុំ ឬក៏វគ្គរៀនសូត្រដែលមាន តាម៉ុក ជាអ្នកបង្រៀន។ ជាដំបូងខ្ញុំចង់ដឹងថា តើលោករៀនសូត្រជាមួយនឹង តាម៉ុក ហ្នឹងតែមួយវគ្គទេ ឬក៏មានច្រើនវគ្គ?

**ឆ៖** ក្នុងកាល តាម៉ុក បង្រៀនខ្ញុំ មានចូលរួមមាន ចាន់ ស៊ី។ ហើយដោយឡែកទៀតទេ តាម៉ុក មិនដែលហៅខ្ញុំបង្រៀនខាងផ្នែកនយោបាយទេ។

[១៣:៤៩:៣២]

**ស៖** កាលម្សិលមិញលោកសាក្សី លោកបានឆ្លើយថា លោកបានចូលរួមវគ្គរៀនសូត្រដែលបង្រៀនដោយ តាម៉ុក។ តើលោកនៅតែរក្សាចម្លើយនេះទេ?

**ឆ៖** ចម្លើយរបស់ខ្ញុំដែលរៀនជាមួយ ជូ ជេត នៅក្នុងនោះមាន តាម៉ុក ដែលគាត់ចុងក្រោយបង្អស់បង្រៀនជិត១ខែចុះ។ ចាន់ ស៊ី ដឹកនាំរៀនមុន ប្រមូលកម្មាភិបាលមូលនៅកន្ទួត។ ក្រោយមក

ទៀត តាម៉ុក ក៏ចូលរួមនៅក្នុងកម្មវិធីរៀនសូត្រនោះដែរ។

**ស៖** សំណួររបស់ខ្ញុំគឺខ្ញុំចង់ដឹងថា -- ខ្ញុំសូមសួររបៀបផ្សេងវិញ។ លោកបានឆ្លើយថាវគ្គរៀនសូត្រជាមួយ ជូ ជេត គឺធ្វើឡើងនៅក្នុងស្រុងថ្កូង ខាងជើងវត្តកែវទក ខ្ញុំសូមទោសបើសិនខ្ញុំអានឈ្មោះនោះមិនត្រូវ។ ពីម្សិលមិញមុនម៉ោងប្រហែលជាម៉ោង១០:០៨នាទី។ តើពិតជានៅកន្លែងហ្នឹងមែនទេដែលលោកបានរៀនសូត្រជាមួយនឹង ជូ ជេត នោះ?

**ឆ៖** ស្រុកថ្កូងនោះ រៀននៅ*(ឮមិនច្បាស់)* អត់រៀននៅខាងជើងវត្ត*(ឮមិនច្បាស់)* នៅអមមាត់ស្ទឹងដែលបានសិក្សារៀនសូត្រចំនួនជិត១ខែ។ នៅទាំងអស់នោះក៏ប្រមូលកម្មាភិបាលគ្រប់ភូមិដែល ជាកម្មាភិបាលខាងផ្នែកនយោបាយដែលកោះហៅទៅតាមភូមិឃុំស្រុកតាមតំបន់គ្រប់ទាំងអស់ដែលកន្លែងដែលជាសាលារៀនហ្នឹង បង្រៀនហ្នឹង--

[១៣:៥២:២៤]

**ស៖** សូមអរគុនលោកសាក្សីដែលបានឆ្លើយបញ្ជាក់។ សូមអភ័យទោសខ្ញុំសូមឲ្យលោកយកចិត្តទុកដាក់ទៅហ្នឹងចម្លើយរបស់ខ្ញុំ។ ខ្ញុំព្យាយាមសួរឲ្យច្បាស់លាស់បំផុតហើយសូមឲ្យលោកឆ្លើយឲ្យច្បាស់ទៅនឹងសំណួររបស់ខ្ញុំ ហើយបើសិនខ្ញុំត្រូវការព័ត៌មានបន្ថែមនោះខ្ញុំនឹងសួរហើយ។ ខ្ញុំមានពេលវេលាតិចណាស់ ហើយប្រសិនបើលោកបន្តឆ្លើយវែងៗបែបនេះគឺថាខ្ញុំមិនអាចបញ្ចប់តាមពេលដែលបានកំណត់នោះទេ។ លោកអម្បាញ់មិញនេះបាននិយាយអំពីវគ្គរៀនសូត្រ។ ប្រសិនបើខ្ញុំមិនច្រឡំទេ គឺថាមុននេះបន្តិចលោកបានឆ្លើយថា ក្នុងពេលរៀនសូត្ររយៈពេល១ខែនោះ គឺថាប្រហែលជានៅចុងវគ្គ តាម៉ុក បានមកធ្វើបទឧទ្ទេសនាម។ ដូច្នេះខ្ញុំចង់ដឹងថា ក្រៅពីវគ្គរៀនសូត្ររយៈពេល១ខែនៅស្រុកថ្កូងនេះ តើលោកមានបានចូលរួមក្នុងវគ្គរៀនសូត្រណាផ្សេងទៀតដែល តាម៉ុក បង្រៀនដែរឬទេ?

**ឆ៖** តាម៉ុក ដែលចូលរួមការសិក្សាដែលខ្ញុំបានលើកឡើងនៅក្នុងវគ្គដែល ជូ ជេត បានបើកនៅសាលាបង្រៀនខាងផ្នែកនយោបាយ។ ក្រោយមកទៀតគេភ្ជាប់គ្នានឹងការសិក្សាហ្នឹងបាន តាម៉ុក មកក្រោយៗ បានដំណើរការ គាត់ដឹកនាំបង្រៀនខាងផ្នែកយោធា។

[១៣:៥៤:២០]

**ស៖** សូមអភ័យទោសលោកសាក្សីដែលខ្ញុំត្រូវកាត់លោកទៀតហើយ។ ខ្ញុំសោកស្តាយណាស់ដែលត្រូវកាត់លោក ក៏ប៉ុន្តែលោកឆ្លើយដដែលៗដូចមុនទៀតហើយ។ សំណួរខ្ញុំមិនមែនអ៊ីចឹងទេលោកសាក្សី។ ខ្ញុំចង់ដឹងថា ក្រៅពីវគ្គរៀនសូត្ររយៈពេល១ខែដែលលោកនិយាយអម្បាញ់មិញនេះ តើក្រៅ

ពីវគ្គរៀនសូត្រមួយហ្នឹងនេះ តើលោកមានចូលរួមក្នុងវគ្គរៀនសូត្រណាមួយដែល តាម៉ុក ដែលជាអ្នកបង្រៀនទៀតទេ នៅពេលណាមួយផ្សេងទៀតនោះ?

**ឆ៖** ខ្ញុំអត់បានចូលសាលាយោធាដែល តាម៉ុក -- ខ្ញុំអត់បានចូលរួមទេហ្នឹងហើយ។

**ស៖** សូមអរគុណលោកដែលបានឆ្លើបញ្ជាក់ត្រង់ចំណុចនេះ។ លោកក៏បានលើកឡើងអំពីឈ្មោះ ហ៊ូ យន់ កាលពីម្សិលមិញពេលនៅម៉ោង១០:២១នាទី សូមផ្អាកបន្តិចសិន ខ្ញុំមើលឯកសារយោងសិន។ នៅម៉ោង១០:២១នាទី។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារសេចក្តីព្រាងប្រតិចារឹកនៅលើអេក្រង់ ដើម្បីឲ្យសាក្សីគាត់អាចពិនិត្យមើល។ កាលពីម្សិលមិញ លោកបានឆ្លើយថា "ហ៊ូ យន់ គាត់មកធ្វើសន្និបាត" ហើយកន្លែងដែលលោកឆ្លើយនោះគឺថា"វត្តតាំងពោធិ៍"។ តើលោកនៅចាំចម្លើយដែលលោកបានឆ្លើយកាលពីម្សិលមិញហ្នឹងទេថា ហ៊ូយន់ គាត់មកធ្វើសន្និបាតនៅវត្តតាំងពោធិ៍?

[១៣:៥៧:២៧]

**ឆ៖** ខ្ញុំបានចូលរួមទាំងកម្មាភិបាល ទាំងថ្នាក់តំបន់ដែលទៅចូលរួម។ និយាយពីការជម្លៀសប្រជាជន ដែលគាត់លើកឡើងនោះថា "បើសិនណាជាយើងវៃឈ្នះ យើងមិនបាច់ជម្លៀសប្រជាជនពីទីក្រុងភ្នំពេញទេ"។ គាត់រៀបរាប់ច្រើនដែរ ប៉ុន្តែគ្រាន់តែខ្ញុំវាបាត់បង់ មិនសូវចាំបានប៉ុន្មានទេ គ្រាន់តែគាត់បញ្ជាក់ថា "យើងបើទទួលបានជ័យជម្នះ--

**ស៖** លោកសាក្សី តើលោកចាំទេ ថានៅឆ្នាំណាដែលលោក ហ៊ូ យន់ មកធ្វើសន្និបាតហ្នឹង? លោកមាននៅចាំអំពីឆ្នាំទេ ឆ្នាំដែល ហ៊ូ យន់ គាត់មកធ្វើសន្និបាតនៅវត្តតាំងពោធិ៍នេះ?

**ឆ៖** ខ្ញុំអត់បានចាំទេឆ្នាំ វាយូរដែរ។ ជម្រាបជូនទៅក៏វាអត់ចាំច្បាស់ អត់ហ៊ានឆ្លើយថា ខែឆ្នាំនេះ ឆ្នាំនោះ។

**ស៖** ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញនូវកំណត់ត្រារបស់លោក ប៉ែន យៀវនិន គឺឯកសារ D313/1.2.405, ERN ជាភាសាខ្មែរ 00909939, ERN ជាភាសាបារាំង 00893548, ERN ជាភាសាអង់គ្លេស 00419461។ ឃ្លាដែលខ្ញុំចង់អាននោះគឺថានៅកណ្តាលទំព័រ។ នេះជាកំណត់ត្រារបស់លោក ប៉ែន យៀវនិន ដែលគាត់បានកត់នៅពេលសម្ភាសន៍លោក។ លោកបានឆ្លើយនៅពេលសម្ភាសន៍ថា "ខ្ញុំបានឃើញ ហ៊ូ យន់ ម្តងនៅឆ្នាំ១៩៧២ នៅវត្តតាំងពោធិ៍ នៅក្នុងពិធី ឬអង្គប្រជុំមួយ។ ខ្ញុំមិនបានជួបនិយាយជាមួយគាត់នោះទេ។ គាត់មិនបានលើកឡើងអំពីវត្តមានរបស់កងទ័ពវៀតណាមនោះឡើយ។ គាត់និយាយតែអំពីចលនាប្រជាជន គាត់និយាយបែបនេះនៅដើមឆ្នាំ១៩៧៣"។ លោក

សាក្សី តើកំណត់ត្រានេះធ្វើឲ្យលោកនឹកឃើញទេ គឺថានៅឆ្នាំ១៩៧២ ឬក៏នៅដើមឆ្នាំ១៩៧៣ លោកបានឃើញ ហ៊ូ យន់ នោះនៅក្នុងសន្និបាតនៅវត្តតាំងពោធិ៍?

[១៤:០១:២៥]

**ឆ៖** ក្នុងឆ្នាំខ្ញុំមិនបានចាំ ហើយនិងខែ។ ដែលនៅចាំលោក ហ៊ូ យន់ ដែលគាត់មកបំភ្លឺដល់កម្មាភិបាល អង្កាល់ណោះគាត់លើកឡើងអំពីដែលត្រូវឈ្នះ គឺយើងមិនត្រូវជម្លៀសប្រជាជនពីទីក្រុងភ្នំពេញនោះទេ។ ហើយខ្ញុំក៏បានស្គាល់គាត់ស្រពិចស្រពិលដែរទេ ដែលគាត់លើកឡើង ដែលហៅកម្មាភិបាលហើយនិងតាមឃុំ តាមស្រុក ខេត្ត តំបន់ហ្នឹងឲ្យមកជួបជុំគ្នានៅវត្តតាំងពោធិ៍ហ្នឹង។ គាត់ប្រកាស គាត់និយាយច្រើនខាងផ្នែកនយោបាយ ប៉ុន្តែខ្ញុំវាការចងចាំហ្នឹងវាភ្លេចបាត់បង់ទៅ តែចាំបានត្រឹមតែគាត់លើកឡើងអំពីជម្លៀសប្រជាជន មិនឲ្យជម្លៀសប្រជាជន។

**ស៖** លោកសាក្សី ទោះបីជាលោកមិនចាំអំពីកាលបរិច្ឆេទក៏ដោយ ក៏ប៉ុន្តែលោកអាចបញ្ជាក់អំពីអ្វីដែលខ្ញុំអានចេញពីកំណត់ត្រារបស់លោក ប៉ែន យៀវនិន គឺថាលោកបានឃើញ ហ៊ូ យន់ នៅវត្តតាំងពោធិ៍ហ្នឹង គឺតែម្តងគត់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែនពិតអ៊ីចឹង។

**ស៖** តើលោកធ្លាប់ចូលរួមក្នុងពិធីប្រជុំ ឬមីទ្ទិងអ្វីផ្សេងទៀតនៅវត្តតាំងពោធិ៍នេះដែរឬទេ?

**ឆ៖** ក្រោយមកអត់បានទៅប្រជុំនៅក្នុងស្រុកថ្គង អត់បានទៅប្រជុំនៅហ្នឹងទេ មានតែនៅក្នុងសមាជិកឃុំ។ សរុបមកវិញហ្នឹងអត់ដែលបានទៅប្រជុំខាងស្រុកថ្គងផង។ ចប់។

[១៤:០៤:៤៥]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់ត្រង់ចំណុចនេះលោកសាក្សី។ ដូច្នេះសរុបទៅ គឺលោកបានឃើញ ហ៊ូ យន់ តែម្តងគត់។ កាលពីព្រឹកមិញនេះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួរលោកមេធាវី កូប៉េ ដែលជាមេធាវីការពារក្តីលោក នួន ជា, លោកបានអះអាងថាលោកមិនដឹងទេថា ហ៊ូ នឹម ប្រឆាំងឬក៏ជំទាស់នឹងការជម្លៀសនោះ។ គឺព្រឹកមិញហ្នឹង គឺនៅប្រហែលជាម៉ោងប្រាំបួនសែសិបប្រាំចន្លោះទៅដល់ម៉ោងដប់ គឺថាលោកអត់ដឹងអំពីជំហររបស់ ហ៊ូ នឹម ទេ មិនដឹងថាគាត់ប្រឆាំង ឬក៏គាត់ជំទាស់នឹងការជម្លៀសទេ។

ឥឡូវនេះខ្ញុំនឹងបង្ហាញជូននៅលើអេក្រង់ ហើយសូមឲ្យលោកមេធាវី គង់ សំអុន អានឃ្លាមួយនៃចម្លើយរបស់លោកកាលពីម្សិលមិញ ដែលលោកបានឆ្លើយថាគោលជំហររបស់លោក ហ៊ូ នឹម និង ខៀវ

សំផន ហ្នឹងគឺដូចគ្នា។ គឺសេចក្ដីព្រាងប្រតិចារឹកនៅម៉ោង ១១:២៣នាទី។ គឺលោកថាលោកមិនដឹងអំពីជំហររបស់អ្នកទាំងពីរនោះទេគឺ ខៀវ សំផន និង ហ៊ូ នឹម។ ដូច្នេះសូមឲ្យលោកមេធាវី គង់ សំអុន គាត់នឹងអានចម្លើយរបស់លោកកាលពីម្សិលមិញ។

[១៤:០៦:២០]

**លោក គង់ សំអុនៈ**

បាទ សូមអនុញ្ញាតអានលោកប្រធាន។ ដកស្រង់ "បើតាមជំហររបស់លោក ខៀវ សំផន គាត់ថាឲ្យជម្លៀស ជម្លៀសប្រជាជន។ ហ៊ូ យន់ គាត់មិនឲ្យជម្លៀសប្រជាជនទេ បើ ហ៊ូ នឹម ក៏គាត់មិនឲ្យជម្លៀសប្រជាជនដែរ ហ៊ូ នឹម"។ បាទ សូមអរគុណលោកប្រធាន។

**ស្ដួរដោយកញ្ញា អង់តា ហ្គីសសេៈ**

**សៈ** លោកសាក្សី យើងខ្ញុំទើបតែអានចម្លើយរបស់លោកកាលពីម្សិលមិញ ដែលលោកឆ្លើយថា "ហ៊ូ នឹម គាត់មិនឲ្យជម្លៀសប្រជាជនទេ ហើយ ខៀវ សំផន នោះគាត់ឲ្យជម្លៀស"។ នេះជាចម្លើយរបស់លោកកាលពីម្សិលមិញ ក៏ប៉ុន្តែនៅព្រឹកមិញនេះ គឺថានៅម៉ោងចន្លោះម៉ោងប្រាំបួនសែសិបប្រាំ និងម៉ោងដប់ លោកឆ្លើយថា លោកមិនដឹងថា ហ៊ូ នឹម ឲ្យជម្លៀសឬក៏មិនឲ្យនោះទេ។ ដូច្នេះតើលោកអាចឆ្លើយបញ្ជាក់ជូនអង្គជំនុំជម្រះឲ្យបានច្បាស់ ថាតើលោកដឹងអំពីជំហររបស់ ហ៊ូ នឹម ច្បាស់ដែរឬទេ គាត់ឲ្យជម្លៀស ឬមិនឲ្យជម្លៀស?

[១៤:០៧:៤៩]

**លោក នូ ម៉ៅៈ**

**ឆៈ** ខ្ញុំមិនបានដឹងទេ ដែលខ្ញុំលើកឡើងពីខាងមុនហ្នឹង ខ្ញុំថា និយាយពី ហ៊ូ យន់ ដែលធ្វើមហាសន្និបាតនៅកន្លែងវត្តតាំងពោធិ៍។ ហើយខ្ញុំមិនដែលស្គាល់ទៀត ហើយ ហ៊ូ នឹម ហើយ ខៀវ សំផន ហ្នឹងក៏ខ្ញុំមិនបានទៅជួបជុំកន្លែងណា ឬក៏ស្គាល់កន្លែងណា ខ្ញុំអត់ទេ។ គ្រាន់តែ ហ៊ូ យន់ ហ្នឹង ដែលគាត់ហៅទៅហ្នឹងខ្ញុំ -- គាត់លើកឡើងថា "បើយើងយកជ័យជម្នះ វ៉ៃឈ្នះ យើងមិនបាច់ជម្លៀសប្រជាជនទេ" ហ្នឹងចំពោះ ហ៊ូ យន់។ ឯលោក ខៀវ សំផន ហើយនិង ហ៊ូ នឹម ខ្ញុំអត់ស្គាល់គាត់ផង អត់ដែលបានជួបគាត់ទេ។

**សៈ** ខ្ញុំយល់អំពីចម្លើយរបស់លោក ក៏ប៉ុន្តែឥឡូវនេះខ្ញុំចង់មេធាវី គង់ សំអុន គាត់អានឃ្លាមួយនៃចម្លើយរបស់លោកកាលពីម្សិលមិញ គឺសេចក្ដីព្រាងប្រតិចារឹកដដែល។ គឺក្រោយម៉ោង១១:២២នាទី

បន្តិច។ ក្នុងនោះលោកនិយាយអំពីជំហររបស់លោក ខៀវ សំផន សំណួររបស់សហព្រះរាជអាជ្ញានៅពេលនោះសួរថា "តើលោកដឹងថា ខៀវ សំផន គាំទ្រផែនការជម្លៀសយ៉ាងម៉េច?" ហើយលោកក៏បានឆ្លើយ។ ឥឡូវនេះសូមឲ្យមេធាវីជាតិអាននូវចម្លើយរបស់លោកជាភាសាខ្មែរ។

[១៤:១០:០៣]

**លោក គង់ សំអុន៖**

សូមអរគុណ។ សូមអនុញ្ញាតអានលោកប្រធាន។ សូមដកស្រង់ "សំណួរ៖ តើធ្វើម៉េចទើបលោកបានដឹងថា ខៀវ សំផន ហ្នឹង គាត់គាំទ្រផែនការជម្លៀស? ឆ្លើយ៖ ខ្ញុំដែលបានដឹងហ្នឹងនៅក្នុងធ្វើសន្និបាតនៅវត្តតាំងពោធិ៍ តែគ្រាន់ខ្ញុំអត់ស្គាល់គាត់ទេ។ ហ្នឹងហើយ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ខ្ញុំអត់ស្គាល់ទេ ទាល់តែគេថា មកធ្វើសន្និបាតនៅតាំងពោធិ៍ហ្នឹង"។ បាទសូមបិទ។ សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដូច្នេះតាមចម្លើយរបស់លោក កាលពីម្សិលមិញយើងយល់ថា នៅក្នុងសន្និបាតនៅក្នុងវត្តតាំងពោធិ៍នេះ លោកបានដឹងអំពីជំហររបស់លោក ខៀវ សំផន និង ហ៊ូ នឹម។ តើលោកអាចពន្យល់ឲ្យបានច្បាស់ទេថា លោកដឹង ឬក៏មិនដឹងអំពីជំហររបស់លោក ខៀវ សំផន និង ហ៊ូ នឹម នេះពាក់ព័ន្ធទៅនឹងផែនការជម្លៀសចេញទីក្រុងភ្នំពេញ?

[១៤:១១:២២៥]

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំបាទខ្ញុំមិនបានដឹងទេ ជំហរ។ ដូចខ្ញុំបានលើកឡើង ខ្ញុំដែលលោក ហ៊ូ យន់ លោកប្រកាសរឿងជម្លៀសប្រជាជនពីទីក្រុង គាត់ថាមិនបាច់ជម្លៀសទេ តែដោយឡែកលោក ខៀវ សំផន និងលោក ហ៊ូ នឹម ខ្ញុំអត់ស្គាល់គាត់ ហើយក៏ចូលក្នុងការសន្និបាតហ្នឹង ក៏ខ្ញុំមិនៗស្គាល់ដែរ។ ហ្នឹងសូមមានតែប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សីដែលបានឆ្លើយបញ្ជាក់។ ឥឡូវនេះខ្ញុំចូលទៅដល់ប្រធានបទផ្សេងទៀត ខ្ញុំជិតចប់ហើយលោកសាក្សី។ លោកបានឆ្លើយថាលោកបានចូលរួម --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោកស្រីមេធាវី!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៤:១២:៤១]

**លោក ឃីត រេយ៍នីរ៖**

លោកប្រធាន ខ្ញុំសូមឲ្យមេធាវីការពារក្ដីបញ្ជាក់នៅក្នុងចម្លើយដែលបានឆ្លើយពីសំណួរមុនហ្នឹងបន្តិច ដោយចេញអានចេញពីប្រតិចារឹកម៉ោង១១:២៨។ ចំណុចដែលខ្ញុំចង់លើកឡើងគឺសំណួរបានសួរថា សាក្សីនេះបានដឹងថា ដឹងអំពីកិច្ចប្រជុំនេះនៅវត្តតាំងពោធិ៍ អំពីជំហររបស់ ខៀវ សំផន និង ហ៊ូ នឹម។ ការដកស្រង់ដើមនៅក្នុងប្រតិចារឹកនោះ តើលោកបានដឹងយ៉ាងម៉េចអំពីជំហររបស់លោក ខៀវ សំផន និង ហ៊ូ នឹម? គឺមិនបានលើកឡើងបញ្ជាក់ ហ៊ូ នឹម ច្បាស់លាស់នោះទេ ក៏ប៉ុន្តែចង្អុលយោងទៅលើចំណុចនេះ។

សំណួរទី២ ដែលខ្ញុំទទួលបាននោះគឺថា តើលោកដឹងទេ អំពីតួនាទីរបស់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការជម្លៀស? សាក្សីនោះគឺមិនបាននិយាយជាក់លាក់អំពីតួនាទីរបស់លោក ខៀវ សំផន នោះទេ គឺនិយាយដោយប្រយោល ហើយក៏មិនបាននិយាយអំពីផែនការជម្លៀសផងដែរ។ ដូច្នេះហើយចំណុចនេះ គួរតែមេធាវីការពារក្ដីសួរបញ្ជាក់ឲ្យបានច្បាស់លាស់។

[១៤:១៤:០៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំយល់អំពីកង្វល់របស់សហព្រះរាជអាជ្ញា ក៏ប៉ុន្តែខ្ញុំបានយកចិត្តទុកដាក់យ៉ាងខ្លាំងគឺថាឲ្យ គឺថាយើងដកស្រង់ជាភាសាខ្មែរតែម្ដង ដើម្បីឲ្យមានបញ្ហាបកប្រែ។ គឺថាអានជាភាសាខ្មែរនូវចម្លើយរបស់សាក្សីដែលជាភាសាខ្មែរ។ ហើយខ្ញុំសួរសំណួរនោះ គឺថាខ្ញុំព្យាយាមបែងចែកឲ្យដាក់រវាង ហ៊ូ នឹម ហើយនិង ខៀវ សំផន។ សាក្សីគាត់ឆ្លើយយ៉ាងច្បាស់ហើយ។ ដូច្នេះសហព្រះរាជអាជ្ញាមិនគួរលើកឡើងបែបនេះនោះទេ។ ខ្ញុំមិនបានសួរជាលក្ខណៈច្របូកច្របល់ទេ គឺថាសួរច្បាស់ណាស់។ ខ្ញុំប្រុងប្រយ័ត្នមែនទែននៅពេលដែលលោកខ្ញុំដកស្រង់ប្រតិចារឹកជាភាសាខ្មែរនោះ ដើម្បីកុំឲ្យមានបញ្ហា។

ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាកុំឲ្យគិតគូរទៅដល់ការជំទាស់របស់សហព្រះរាជអាជ្ញាអី ហើយសូមអនុញ្ញាតឲ្យខ្ញុំបញ្ចប់ការសួរសំណួររបស់ខ្ញុំ ដែលថាខ្ញុំជិតចប់ហើយសល់តែបន្តិចទៀតទេ។

[១៤:១៥:២៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៦:០១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីបន្តសំណួរទៅមុខទៀត ហើយសូមបញ្ជាក់ផងដែរថា តើត្រូវការពេលវេលាប៉ុន្មានទៀត ពីព្រោះការសុំពេលវេលា ៤៥នាទី ដូចជាផុតហើយ?

សុំផ្អាកបន្តិច!

សូមអញ្ជើញលោក នូ ម៉ៅ!

*(សម្រាករយៈពេលខ្លី)*

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១៤:១៨:១៨]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមិនដឹងអំពីបញ្ហាស្ថានភាពសុខភាពរបស់លោកសាក្សីយ៉ាងម៉េចនោះទេ ខ្ញុំត្រូវការតែពេល៥នាទីបន្ថែមទៀតទេលោកប្រធាន ដើម្បីសួរពាក់ព័ន្ធនឹង តាម៉ុក ហើយប្រសិនបើគាត់មិនអាចឆ្លើយនឹងសំណួរបានទេ ខ្ញុំអាចបញ្ចប់ក៏បានដែរ លោកប្រធាន អត់បញ្ហាអីទេ។ ប្រសិនបើគាត់មិនអាចឆ្លើយបានក្នុងរយៈពេល ៥នាទីបាន ខ្ញុំក៏មិនមានបញ្ហាអ្វីដែរ ខ្ញុំសូមបញ្ចប់ត្រឹមហ្នឹងតែម្តងទៅ ព្រោះថាគាត់មានបញ្ហាសុខភាព។ ដូច្នេះអានេះទៅតាមការសម្រេចរបស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន ខ្ញុំក្រោកឈរនៅពេលនេះដោយសារតែភស្តុតាងនៅក្នុងនេះគឺមិនទាន់បានបំពេញ ហើយខ្ញុំមិនទាន់ពេញចិត្តនៅឡើយ។ ប្រសិនបើព្រះរាជអាជ្ញាមានសិទ្ធិពិនិត្យទៅដេញដោលលើភស្តុតាងនោះគឺថាល្អ។ យើងលើកឡើងអំពីពាក្យថា “ជំហរ” ហើយចម្លើយនោះគាត់បានឆ្លើយថា “ខ្ញុំមិនស្គាល់គាត់”។ ចំណុចនេះគឺថាវាជាភស្តុតាងមួយសំខាន់ដែលវាមិនបានបញ្ជាក់បំភ្លឺពីខាងមេធាវីការពារក្តី។ ខ្ញុំមិនមានលទ្ធភាពសួរបញ្ជាក់ទៅលើចំណុចហ្នឹង។ ដូច្នេះបានន័យថាការសួរដេញដោល គឺវាត្រង់ចំណុចនេះ។ អ្វីដែលខ្ញុំចង់ស្នើឡើង គឺឱ្យលោកចៅក្រមណាម្នាក់នៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនេះអាចសួរបញ្ជាក់ទៅលើចំណុចហ្នឹងឱ្យបានច្បាស់ទោះក្នុងដំណាក់កាលណាក៏ដោយ។

[១៤:២១:២១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំគិតថាអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងប្រធានបទនេះហើយ។ ដូច្នេះខ្ញុំមិនយល់តើហេតុអ្វីបានជាគាត់លើកឡើងអំពីបញ្ហាហ្នឹងទៀតទេ។ ខ្ញុំបញ្ជាក់ថា--

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីបន្តសំណួរចុងក្រោយរបស់លោកស្រី ដែលស្រីថាប្រើប្រាស់ពេលវេលាតែ៥នាទីទៀតទេ។ បញ្ហាផ្សេងទៀត យើងមិនអនុញ្ញាតឲ្យធ្វើឡើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ចំណុចចុងក្រោយដែលខ្ញុំចង់ពិភាក្សាជាមួយលោក គឺពាក់ព័ន្ធនឹង តាម៉ុក។ លោកឆ្លើយបានថាគាត់ទទួលបន្ទុកខាងយោធា។ នៅចំពោះមុខតុលាការយើងនេះ គឺសាក្សី ឈូក រិន ដែលជាយោធានោះ គាត់បានមកផ្តល់សក្ខីកម្ម។ ខ្ញុំចង់សួរលោកសិនថា តើលោកស្គាល់លោក ឈូក រិន ដែរឬទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំអត់បានស្គាល់ទេ។

**ស៖** នៅសវនាការថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ គឺក្រោយម៉ោង ១១:២៣ បន្តិច ហើយនិងក្រោយម៉ោង ១៥:៤៩នាទីផងដែរ។ សាក្សីគាត់បានឆ្លើយថា តាម៉ុក គាត់បានប្រើពាក្យស្លោកមួយដែលថា"នៅលើ ម៉ុក មានតែមួក"។ ដូច្នេះ ខ្ញុំការអនុញ្ញាតពីលោកប្រធានដើម្បីបញ្ជាក់ពាក្យស្លោកនេះជាភាសាខ្មែរ គឺបញ្ចាំងសម្រង់នៃប្រតិចារឹកសវនាការថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ គឺឯកសារ E1/182.1 គឺក្រោយម៉ោង ១៥:៤៩នាទី។ គឺឈូក រិន គាត់បានរៀបរាប់អំពី តាម៉ុក "នៅពេលដែលតាម៉ុក បញ្ជាឲ្យកងកម្លាំងធ្វើអីមួយ ឧទាហរណ៍ដូចជាទៅប្រយុទ្ធ គឺត្រូវតែធ្វើតាមគាត់។ ប្រសិនបើខ្ញុំរាយការណ៍មិនល្អទេ គាត់ដកកាំភ្លើងមកអាចបាញ់យើង។ ជួនកាលគាត់ល្អ ជួនកាលគាត់កាចណាស់។" សូមបញ្ចប់ការដកស្រង់។

[១៤:២៤:៣០]

លោកសាក្សី នៅភូមិភាគបស្ចិមនិងពាយ័ព្យ តើលោកធ្លាប់ឮអំពីរឿងរ៉ាវដូចគ្នាស្រដៀងនឹង តាម៉ុក នេះដែរទេ? ហើយលោកដឹងទេថា ត្រឹមត្រូវដែរឬទេអំពីបញ្ហាហ្នឹងពាក់ព័ន្ធនឹង តាម៉ុក នោះលោក?

**ឆ៖** ខ្ញុំរកនឹក មិនចាប់បានទេត្រង់ហ្នឹង ដូចថាវាយូរពេកទៅហើយនៅក្នុងឯកសារហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសាក្សី ឥឡូវនេះខ្ញុំទុកឱ្យលោកសម្រាកហើយព្រោះថាខ្ញុំអស់សំណួរហើយ។

សូមអរគុណលោកប្រធានដែលបានផ្តល់ពេលវេលា៥នាទីបន្ថែមឱ្យខ្ញុំសួរសំណួរបញ្ចប់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមឆ្លើយតបទៅនឹងយោបល់របស់តំណាងសហព្រះរាជអាជ្ញាប៉ុន្មាននាទីមុននេះ។ យើងគ្រាន់តែចង់លើកឡើងថា យើងកត់សម្គាល់ទៅលើយោបល់នេះ ហើយយើងនឹងយកទៅពិចារណានៅពេលដែលអង្គជំនុំជម្រះវាយតម្លៃទៅលើភស្តុតាងរបស់សាក្សីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។ លោក នូ ម៉ៅ ការស្តាប់សក្ខីកម្មរបស់លោករហូតមកដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល ២ថ្ងៃកន្លងមកនេះ ដោយភាពអត់ធ្មត់ និងខិតខំអស់ពីសមត្ថភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ ហើយសូមជូនពរលោកឱ្យមានសុខភាពល្អ ឱ្យជួបតែសំណាងល្អបានសេចក្តីសុខសេចក្តីចំរើន។

ហើយសវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃច័ន្ទទី២៤ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃច័ន្ទ ដើមសប្តាហ៍ក្រោយនេះអង្គជំនុំជម្រះនឹងធ្វើសវនាការការបង្ហាញឯកសារគន្លឹះរបស់ភាគីចំពោះមុខអង្គជំនុំជម្រះ ឬ/និងរបស់អង្គជំនុំជម្រះចំពោះមុខ

ភាគី។ សូមភាគីនៃរឿងក្ដី បុគ្គលិកគាំទ្រកិច្ចដំណើរការរបស់អង្គជំនុំជម្រះសាលាដំបូងនិងសាធារណ-ជនជ្រាប។

សូមអញ្ជើញលោក លោកស្រីមេធាវី!

[១៤:២៨:៤០]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។

ខ្ញុំសូមមកធ្វើការអត្ថាធិប្បាយបន្តិចបន្តួចបើសិនជាខ្ញុំយល់មិនច្រឡំទេ ដែលទាក់ទងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនេះដែលចេញដោយចៅក្រមខាតវ៉ាយថ៍ អម្បាញ់មិញនេះ គឺថាសេចក្ដីសម្រេចហ្នឹងនឹងគិតអំពីការកត់សម្គាល់របស់សហព្រះរាជអាជ្ញាផងដែរ ហើយខ្ញុំក៏មិនមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងការកត់សម្គាល់ដែរ។ អ៊ីចឹងខ្ញុំចង់ជម្រាបជូនថា បើសិនជាចៅក្រមចង់ចេញសេចក្ដីអ្វីនោះត្រូវតែទុក រក្សា ផ្ដល់សិទ្ធិឲ្យយើងខ្ញុំឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។ អ៊ីចឹងបើសិនជាតុលាការយកការកត់សម្គាល់របស់សហព្រះរាជអាជ្ញាត្រូវតែគិតពីគំនិតយោបល់ខាងការពារក្ដីផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក នូ ម៉ៅ ត្រឡប់ទៅកាន់គោលដៅណាដែលគាត់មានបំណងចង់ទៅ ឬក៏ទៅលំនៅដ្ឋានរបស់គាត់វិញចុះ។ ហើយលោក នូ ម៉ៅ ហើយនិងលោក ម៉ម រិទ្ធា គឺលោកអាចចាកចេញពីបន្ទប់សវនាការនេះបានហើយ។ អង្គជំនុំជម្រះនូវមានបញ្ហាមួយចំនួនទៀត ត្រូវជជែកវែកញែកចុងក្រោយ។

អញ្ជើញភាគីទាំងពីរចង់និយាយអី សូមអញ្ជើញ!

[១៤:៣១:០០]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ បើសិនជាខ្ញុំយល់មិនច្រឡំទេ ការកត់សម្គាល់របស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ គឺថា គាត់ចង់និយាយថា មានការច្របូកច្របល់ក្នុងការចោទសំណួរ ដោយប្រើពាក្យ “គោលជំហរ” ទាក់ទងនឹងគោលជំហររបស់លោក ខៀវ សំផន អម្បាញ់មិញនេះ។ យើងមិនទាន់បានប្រតិចារឹកសម្រាប់ថ្ងៃនេះទេ។ យើងនឹងទទួលបានប្រតិចារឹកនេះ។ ក៏ប៉ុន្តែយ៉ាងច្បាស់ណាស់នៅ

ពេលដែលសាក្សីឆ្លើយទៅនឹងសំណួររបស់ខ្ញុំ នៅពេលដែលខ្ញុំសួរគាត់ថាតើគាត់ដឹងអំពីគោលជំហររបស់លោក ខៀវ សំផន ទាក់ទងនឹងការជម្លៀសដែរឬក៏អត់នោះ។ នៅក្នុងការបកប្រែជាភាសាបារាំង ខ្ញុំមិនដឹងថាគេបកទៅជាភាសាអង់គ្លេសយ៉ាងម៉េចនោះទេ។ គឺថាខ្ញុំឮជាភាសាបារាំងថា "គាត់ដឹងអំពីគោលជំហររបស់ ហ៊ូ យន់ ពីព្រោះថា ហ៊ូ យន់ បានប្រាប់អំពីគោលជំហររបស់ខ្លួនទៅកាន់គាត់ នៅពេលដែលគាត់បង្រៀននយោបាយនៅវត្តតាំងពោធិ៍"។ ប៉ុន្តែសាក្សីនេះមិនដឹងអំពីគោលជំហររបស់លោក ខៀវ សំផន នោះទេ ហើយក៏មិនដឹងអំពីគោលជំហររបស់ ហ៊ូ នឹម ផងដែរទាក់ទងទៅនឹងការជម្លៀសនេះ។ នេះច្បាស់ណាស់ បើតាមខ្ញុំស្ដាប់បកប្រែ។

[១៤:៣២:២២]

ដូច្នេះថ្ងៃនេះ ទោះបីថាព្រះរាជអាជ្ញាចង់និយាយថា មានការច្របូកច្របល់ នេះមិនអាចទៅរួចទេ។ នេះជាច្រើនដងណាស់មកហើយ ថាមានការធ្វើដូច្នេះពីសហព្រះរាជអាជ្ញានេះច្រើនដងមកហើយ។ អ៊ីចឹងអង្គជំនុំជម្រះត្រូវតែកត់សម្គាល់ថា សាក្សីនេះនិយាយជាទូទៅ អាចថាគាត់ច្រឡំ អាចគាត់និយាយផ្ទុយ ឬក៏ជួនកាលនោះ សំណួរមួយចំនួននោះ ហាក់ដូចជាការបញ្ឆោតគាត់ទៅវិញ។ អ៊ីចឹង ទោះយ៉ាងណាក្ដីសាក្សីពិតជាបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ហើយគាត់ពិតជាបានឆ្លើយថា គោលជំហររបស់លោក ខៀវ សំផន ទាក់ទងនឹងគោលជំហររបស់លោក ខៀវ សំផន, ទាក់ទងនឹងការជម្លៀសនេះ គាត់ឆ្លើយច្បាស់លាស់ហើយ។ អ៊ីចឹងនៅពេលដែលព្រះរាជអាជ្ញានិយាយថា មានការច្របូកច្របល់ ពីព្រោះថាចម្លើយសាររបស់សាក្សីនេះ ធ្វើឲ្យគាត់មិនពេញចិត្តនោះ អ៊ីចឹងនៅពេលដែលខ្លួនមិនពេញចិត្តនឹងសំណួរអ្វីមួយដោយសារសាក្សីនេះឆ្លើយពីដំបូងថាគាត់មិនដឹងអំពីគោលជំហររបស់លោក ខៀវ សំផន។ ហើយត្រង់ចំណុចនេះ គឺថាវាមិនមែនជាការពិតនោះទេ អ្វីដែលនិយាយក្នុងសវនាការនេះ ខុសពីហ្នឹង។

អ៊ីចឹង ខ្ញុំសូមឲ្យតុលាការគិតពីបញ្ហានេះ គិតពីការកត់សម្គាល់របស់ព្រះរាជអាជ្ញា ហើយក៏គិតពីការកត់សម្គាល់របស់ខាងការពារក្ដីផងដែរ ហើយយើងនឹងមានប្រតិចារឹកនៅពេលក្រោយ។ យើងនឹងផ្ទៀងផ្ទាត់បាន។ នេះជាការកត់សម្គាល់របស់ខ្ញុំលោកប្រធាន។

[១៤:៣៤:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

**លោក ឃឹត រេយ៉ន័រ៖**

ខ្ញុំនឹងលើកឡើងសង្ខេបទេលោកប្រធាន។ នៅពេលសំណួរដែលសួរទាញយកចម្លើយថា "ខ្ញុំមិនបានស្គាល់នោះទេ ពាក់ព័ន្ធនឹងលោក ខៀវ សំផន"។ បានន័យថា នៅពេលនោះហើយ សាក្សីគាត់ជឿថាសំណួរនោះ គឺចង់សួរគាត់ថា តើស្គាល់ ខៀវ សំផន ឬក៏មិនស្គាល់? បន្ទាប់មកប្រើពាក្យថា "ជំហរ" ថាតើលោកដឹងអំពីជំហររបស់លោក ខៀវ សំផន ដែរឬទេ? ពេលនោះសួរអំពីឋានន្តរក្រម។ ដូច្នេះ អ្វីដែលខ្ញុំសូមឲ្យអង្គជំនុំជម្រះពិចារណា ត្រូវមើលប្រតិចារឹកនៅពេលដែលនិយាយអំពីជំហររបស់លោក ខៀវ សំផន នេះ។ ហើយត្រូវតែពិចារណាទៅលើប្រតិចារឹកកាលពីម្សិលមិញនៅម៉ោង១១:៣៨ ដែលក្នុងនោះមិនបានលើកឡើងអំពីបញ្ហាលោក ហ៊ូ នឹម នោះទេ។ ខ្ញុំបានសួរថា "តើលោកបានដឹងថា ខៀវ សំផន និង ហ៊ូ នឹម យ៉ាងម៉េចអំពីជំហរការជម្លៀសប្រជាជននៅពេលនោះ?"។ ដូច្នេះបញ្ហាទាំងអស់នេះ គឺថាអង្គជំនុំជម្រះគួរពិចារណាទៅលើប្រតិចារឹកកាលពីម្សិលមិញ និងរួមទាំងប្រតិចារឹកក្នុងថ្ងៃនេះផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

[១៤:៣៥:៥៤]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន អ៊ីចឹងយ៉ាងហោចណាស់យើងយល់ស្របគ្នាត្រង់ចំណុចមួយ គឺថាចំណុចហ្នឹង គឺថាយើងត្រូវតែផ្អែកទៅលើប្រតិចារឹកសវនាការនេះ។ ខ្ញុំរំពឹកថា ប្រសិនជាខ្ញុំខំប្រឹងប្រយ័ត្នថាក្នុងការរៀបរាប់ ឬក៏ដកស្រង់ជាភាសាខ្មែរនៃចម្លើយរបស់សាក្សីនេះ ដោយសារខ្ញុំមិនចង់ឲ្យមានការភ័ន្តច្រឡំ។ អ៊ីចឹងអង្គជំនុំជម្រះនឹងមានប្រតិចារឹក។ អ៊ីចឹងដោយសារថា អ៊ីចេះ ការបកប្រែដែលយើងទទួលបានព្រះរាជអាជ្ញាគាត់ទទួលបានផ្សេង, ខ្ញុំទទួលបានផ្សេង។ អ៊ីចឹងហើយយើងនឹងយោងទៅលើប្រតិចារឹក។ នេះជាការ -- ខ្ញុំសូមបញ្ចប់ការកត់សម្គាល់ខ្ញុំត្រឹមតែតែម្តងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ហើយសូមជម្រាបជូនភាគីនៃរឿងនេះថា អង្គជំនុំជម្រះប្រាកដណាស់ គឺនឹងផ្អែកលើប្រតិចារឹកដែលកត់ត្រានូវដំណើរការសវនាការនេះជាមូលដ្ឋានក្នុងការពិចារណាវាយតម្លៃលើភស្តុតាងនៅក្នុងសំណុំរឿងក្តីនេះទាំងអស់។ គឺជាការវិភាគ ការវាយតម្លៃសរុបរួមតែម្តង។ មិនមែន

វាយតម្លៃតែកំណត់ហេតុប្រតិចារឹកម្សិលមិញ ហើយចោលថ្ងៃនេះ ហើយពិនិត្យតែថ្ងៃនេះ ចោលអំពីប្រតិចារឹកកាលពីម្សិលមិញ ឬក៏ដែលបានធ្វើក្នុងអំឡុងពេលមកនោះឡើយ។ សូមជ្រាប ហើយនិងសូមបញ្ជាក់ឲ្យបានច្បាស់លាស់។

[១៤:៣៧:២៧]

បាទ ឥឡូវនេះបើមិនមានបញ្ហាអីទៀតទេ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការនេះត្រឹមនេះសាជាថ្មីម្តងទៀត ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបមកចូលរួមសវនាការនេះវិញនៅថ្ងៃចន្ទទី២៤ ខែមិថុនា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៤:៣៨ នាទី)*